# KhmerPost USA

សុបិន : (267) 253-3947, សែម : (781) 244-0522

Vol 06 Issue 116 Oct. 26 - Nov. 8th. 2012


## លេខពិសេសសម្រាប់ នរោត្តម សីហនុ
### រាយការណ៍ជុំវិញព្រឹត្តិការណ៍ សីហនុ


១-សូមលោកអ្នកចេញទៅបោះឆ្នោត.....០៣
២-សុខភាព និងម្ហូបអាហារយើង.....០៤
៣-The Cambodia daily.....០៦&០៩
៤-ទស្សនៈមតិជុំវិញការសោយទិវង្គតអតីត.....០៧
៥- មតិមិត្តអ្នកអាន.....០៨
៦-ខ្មែរនៅស.រ.អាធ្វើបាតុកម្មគាំទ្រថ្ងៃទី២៣តុលា ឆ្នាំ១០០១.....១១


## វិចារណកថា

## សម្ភាសន៍ជាមួយ ផូលីយុ យែលជ្រេល អ្នកសរសេរជីវប្រវត្តិន.សីហនុ

ប្រែសម្រួលដោយ ពិន ពិទូ



▸ អតីតព្រះវីរមហាក្សត្រនរោត្តម សីហនុ ដែលព្រះអង្គបានរក្សានូវព្រះកិត្តិនាមដែលមិនចេះសាបសូន្យជាមួយនឹងស្នាព្រះហស្តនៃការដឹកនាំប្រទេសជាតិនៅក្នុងអំឡុងទសវត្សរ៍ដែលប្រទេសរបស់ព្រះអង្គទទួលបាននូវសន្តិភាព និងរងនូវវិបត្តិនយោបាយយ៉ាងរីករវរ។ **តទៅទំព័រទី ១៥**

# ការចូលទិវង្គត និងព្រះរាជប្រវត្តិ របស់សម្ដេច នរោត្តមសីហនុ



**អ៊ឹម លឿម** : ការចូលទីវង្គតរបស់សម្តេចព្រះនរោត្តម សីហនុ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ កន្លងមកនេះបានបញ្ចាំងឱ្យមានការសោកសង្រេកស្តាយស្រណោះអាឡោះអាល័យ និងសំដែងនូវការកាន់ទុក្ខយ៉ាងក្រៀមក្រំពីសំណាក់ **តទៅទំព័រទី ១៥**


I VOTED !

OUR Generation . OUR Future . OUR Life

ខ្ញុំបានបោះឆ្នោត!

ដើម្បីខ្លួនយើង ដើម្បីអនាគតយើង ដើម្បីជីវិតយើង

**Election Day**

Tuesday, November 6, 2012

ថ្ងៃបោះឆ្នោត

ថ្ងៃអង្គារ ទី ៦ ខែ ១១ ឆ្នាំ២០១២

Voting booth lacation and other info.
**www.votespa.com**
Voter Registration Admin: 1.877.868.3772
CAGP: 215.324.4070

This reminder was brought to you by
Cambodian Association of Greater Philadelphia
www.Cagp.org/5412 N.5th St.Phila., PA 19120



Voting booth lacation and other info.
**www.votespa.com**
Voter Registration Admin: 1.877.868.3772
CAGP: 215.324.4070

This reminder was brought to you by
Cambodian Association of Greater Philadelphia
www.Cagp.org/5412 N.5th St.Phila., PA 19120



BUY RITE Pharmacy

Nhà Thuốc Tây 藥房 ឱសថស្ថាន

267-297-5879

# ឱសថស្ថាន ថាច់ សូមស្វាគមន៍

• ឱសថការី ដាន់ ថាច់ មានសេចក្តី រីករាយ និងបំរើសុខភាពបងប្អូនក្នុងសហគមន៍ឱ្យបានប្រសើរ ។




• ភ្ញៀវដែលមកទិញថ្នាំតាមវេជ្ជបញ្ជាទាំងថ្មីទាំងចាស់ អាចនឹងត្រូវឆ្នោតទទួលរង្វាន់ ដូចរូបខាងក្រោម ថ្ងៃទី៣១ ខែធ្នូ ២០១២
• យើងជូនកូប៉ុងដូចអ្នកឯទៀត
• ចុះថ្លៃពិសេសជូនព្រឹទ្ធាចារ្យ ។

• ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ • ទទួលអ៊ិនស្វ៊ិនស្វើរគ្រប់មុខ • ទទួលបន្តផ្តល់ថ្នាំដែលលោកអ្នកកំពុងប្រើ ទិញមកពីឱសថស្ថានផ្សេងៗ
• តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ • ផ្តល់សេវាដោយរហ័សទាន់ចិត្ត
• មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

**1337 W.Rockland St.Philadelphia, PA 19141(Corner of Old York Rd & Rockland St.)**
**Tel: 267-297-5879 Fax: 267-297-5880**





Angkor Restaurant

Ben city Plaza

# ភោជនីយដ្ឋាន អង្គរ

Angkor Restaurant



5520 Whitaker Ave, Unit 7 Philadelphia, Pa 19124 Phone: 215.831.1016

អាចបញ្ជាឲ្យធ្វើម្ហូបត្រៅ "មេញ" បានមានម្ហូបអាមេរិកាំង ម្ហូបអាស៊ីជាដើម

មានធ្វើម្ហូប VG សម្រាប់អ្នកមិនពិសាសាច់

## ភោជនីយដ្ឋាន ម្ហូបខ្មែរ ទើបបើកថ្មី !
### នៅហ្វីឡាដែលហៀខាងជើង

សូមអញ្ជើញមកពិសារម្ហូបខ្មែរគ្រប់មុខ ចំអិនដោយចុងភៅខ្មែរស្ទាត់ជំនាញ នាភោជនីយដ្ឋានធំទូលាយ បំរើម្ហូបខ្មែរពិតប្រាកដដ៏ឈ្ងុយឆ្ងាញ់ អ្នកបំរើភ្ញៀវរួសរាយ **មានកន្លែងចតរថយន្តគ្រប់គ្រាន់ !**



# សូមលោកអ្នកចេញទៅបោះឆ្នោត




**ខ្មែរផុស ស.រ.អា**

បោះឆ្នោតប្រធានាធិបតី ស.រ.អា នឹងប្រព្រឹត្តទៅនៅថ្ងៃទី៦វិច្ឆិកា ឆ្នាំ ២០១២ គឺនៅបាំងតែ១ អាទិត្យទៀតសោះដែលលោកអ្នកជាដើមកំណើតខ្មែរធ្លាប់រអ៊ូថា មិនមានសិទ្ធិនៅក្នុងស្រុកខ្មែរ ឥឡូវសិទ្ធិជាខ្មែរអាមេរិកាំងមានពេញលេញ ការចេញទៅបោះឆ្នោតលើកនេះ នឹងមានន័យសម្រាប់ជីវិតខ្លាំងណាស់ ។

មានន័យ គឺស្ថិតនៅលើតម្លៃលោកអ្នកដែលជាអ្នកជ្រើសរើសប្រធានាធិបតី ដោយខ្លួនឯងបានអាចជ្រើសរើសយកអ្នកដែលធ្វើការឱ្យលោកអ្នកឱ្យមានការងារធ្វើថ្លៃថ្នូររកតម្រែមកចិញ្ចឹមគ្រួសារយកអ្នកដែលយកចិត្តពីការចិញ្ចឹមបីបាច់កូនចៅឱ្យទៅរៀនសូត្របានខ្ពស់ទៅបាន -យកអ្នកដែលយកចិត្តទុកដាក់ពីការរីកចំរើននៃភូមិខ្មែរសំអាតក្រុងពីក្រុមក្មេងពីភាពស្មោគគ្រោក-យកអ្នកដែលទុកចិត្តថា នឹងមើលទៅកម្ពុជាឱ្យថ្មុំថ្មើងជួយដល់បងប្អូនយើងដែលកំពុងរស់នៅទីនោះឱ្យបានសុខសាន្ត...ទាំងនេះ បងប្អូន ខ្មែរអាចឃើញច្បាស់ តម្លៃនៃការជ្រើសរើសមានពិតប្រាកដឬទេ? នៅបាំង ១សប្តាហ៍ទៀតនេះ ។

សមាគមខ្មែរបានធ្វើការអំពាវនាវរំលឹកពីសិទ្ធិនិងអញ្ជើញលោកអ្នកឱ្យប្រើសិទ្ធិនោះ កុំបីខាន ហើយក៏អញ្ជើញអ្នកចេះដឹងច្រើន ឱ្យនាំគ្នាស្ម័គ្រចិត្តយកពេលវេលាខ្លះទៅជួយណែនាំអ្នកដែលយល់ដឹងតិចតួចពីសិទ្ធិបោះឆ្នោត ឱ្យអាចបំពេញភារកិច្ចដ៏ខ្ពង់ខ្ពស់នេះជាប្រយោជន៍ដល់គ្រួសារនិងសហគមន៍ខ្លួនឯងមានប្រសិទ្ធិភាព ។ ប្រមាណជា១០ឆ្នាំចុងក្រោយនេះ បងប្អូននៃសហគមន៍ខ្មែរបានកើនចំនួនពី៣-៤ភាគរយទៅដល់ប្រមាណជា១០-១៥ភាគរយ នាំគ្នាទៅបោះឆ្នោតតែចំនួននេះនៅតិចតួចពេកណាស់ ដែលធ្វើឱ្យទំហំការងារអ្នកបំរើសហគមន៍ខ្មែរចុះថយ-ទំហំថវិកាថែរទាំសុខភាពសង្គមខ្មែរមានតូចទាប-សោភ័ណភាពភូមិក្រុងដែលលោកអ្នករស់នៅអាប់អួរ... ។ល ។ ប្រសិនបើចំនួនខ្មែរចេញទៅបោះឆ្នោតបែរជាកើនទៅជា៥០ភាគរយ យ៉ាងតិចទៅវិញ គេនឹងឃើញសហគមន៍ខ្មែរនៅតំបន់នោះនឹងរីកចំរើនយ៉ាងឆាប់រហ័សភ្លាមបាន ។

ថ្ងៃទី៦ខែវិច្ឆិកានេះ លោកអ្នកជាអ្នកជ្រើសរើសប្រធានាធិបតីអារេមិកាំងក្នុងចំណោមគណបក្សធំពីរ គឺគណបក្ស សាធារណរដ្ឋ តំណាងដោយ មីត រ៉មនី នឹង ផល ប្រាយ៉ីន នឹងគណបក្សប្រជាធិបតេយ្យ តំណាងដោយ ប៉ារ៉ាក អូបាម៉ា និងជោ បាយដិន ។ តំណាង ទាំងពីរក្រុមនេះ បានធ្វើការឃោសនា ជាច្រើនខែមក ហើយ ហើយចុងក្រោយនេះបានធ្វើការប្រឈមមុខដេញដោលគ្នា និងដេញដោលដោយប្រព័ន្ធផ្សព្វផ្សាយ សេរី ដើម្បីឱ្យម្ចាស់ឆ្នោតយល់ជឿនឹងបោះឆ្នោតឱ្យខ្លួន ។ ចំណុចក្តៅនៃនយោបាយបច្ចុប្បន្ន គឺក្នុងស្រុកមានបញ្ហាថវិកាជំនួយសុខ ភាពសេដ្ឋកិច្ចចុះអន់ថយនៃស.រ.អា ចំនួននៃអ្នករកការងារធ្វើ នៅខ្ពស់ជាង៨ភាគរយនៅឡើយ-ការកែទម្រង់គ្រប់គ្រងសិក្សាធិការ-ធានាគារអចលនវត្ថុមិនទាន់មានលំនឹងមកវិញនៅឡើយ... ក្រៅប្រទេសការដកទ័ពអាមេរិកាំងពីតំបន់ចម្បាំងនានា តែអាមេរិកនៅតែទទួលការគម្រាមកំហែងនៅតែខ្លាំងនៅឡើយ ដូច្នេះអ្នកបោះឆ្នោតម្នាក់ៗ ត្រូវតាមដានពិគ្រោះយោបល់ឱ្យបានច្រើនតែត្រូវធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងថាសន្លឹកឆ្នោត១សន្លឹករបស់ខ្លួននឹងបោះឱ្យបេក្ខជនណាមួយ? ហើយបោះឆ្នោតដោយ

តទៅទំព័រទី ១៦


## ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**



## ខ្មែរជួសជុលរថយន្ត
## KHMER AUTO REPAIR

CAR INSPECTION, DIAGNOTIC & REPAIR

**ត្រួតពិនិត្យរថយន្តបញ្ជរដ្ឋ**
- ▸ ដែករកកន្លែងខូចខាត និងជួសជុល
- ▸ យើងធ្វើហ្វ្រាំង ឬប្រេក
- ▸ ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- ▸ បញ្ចេះឡានអាល់ទេណាទ័រ
- ▸ បូមចរន្តទឹករេឌីណាទ័រ
- ▸ សេវាត្រង់បីស្បង
- ▸ មើលតម្រងទ្រនាប់ និងពីញង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634



## MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីគ្រោះថ្នាក់ដល់រូបរាងកាយ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងលែងប្តីប្រពន្ធ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

- Personal Injury
- Family Law & Divorce
- Disability
- Traffic Accidents
- Sex & Drug Crimes, OUI
- Work Accidents

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

www.marcottelawfirm.com

# សុខភាព និងម្ហូបអាហារយើងបរិភោគ

អ្នកឧបត្ថម្ភ

ពព័លេខមុន

| Nutrition Information: | |
|---|---|
| **Ginger Stir Fry with Chicken** | |
| Serving Size: 1½ cups vegetables & meat, 1 cup rice | |
| Nutrition Information Per Serving | |
| Calories 445 | Calories from Fat 75 |
| | % Daily Value* |
| Total Fat 8 g | 12% |
| Saturated Fat 1 g | 5% |
| Cholesterol 50 mg | 17% |
| Sodium 470 mg | 20% |
| Total Carbohydrate 62 g | 21% |
| Dietary Fiber 6 g | 24% |
| Sugars 9 g | |
| Protein 27 g | |
| Iron 2.2 mg | 12% |
| Calcium 70 mg | 7% |

*Percent Daily Values are based on a 2,000 calorie diet. Your Daily Values may be higher or lower depending on your calorie needs.

If you have high blood pressure and are trying to eat less sodium, you should look at the section for sodium. You can see each serving of this recipe has 470 mg of sodium, which is 20% of the maximum amount of sodium that we should eat each day. This recipe uses less oyster sauce, less fish sauce, and reduced sodium soy sauce, so it has much less sodium than it would have if it were made the usual way.

The box with detailed nutrition information looks a lot like the "Nutrition Facts" box that is printed on food labels at the grocery store. It has information about how many servings each recipe makes, how big a serving is, and it gives nutrition information about each serving. It tells how many calories are in a serving. The box also tells how much fat, saturated fat, cholesterol, sodium, carbohydrates, fiber, sugar, protein, iron, and calcium are in each serving of the recipe if it is prepared following the measurements in the instructions. These things are called nutrients. If we should eat more of a nutrient, the box is colored green. If we should eat less of a nutrient, the box is colored pink.

For example, this box is for Ginger Stir Fry with Chicken, which is on page 29. This recipe makes 4 servings, and each serving is 1½ cups of vegetables and meat, and 1 cup of cooked brown rice. Each serving has about 445 calories.

## ឆាខាត់ណាទឹកខ្យង

### គ្រឿងផ្សំ

- ខាត់ណា ២ ផោន
- ប្រេងកាណូឡា ១.៥ ស្លាព្រា
- ខ្ទឹមសចិញ្ច្រាំ ១ កំពឹស
- ទឹកខ្យង ១.៥ ស្លាបព្រា
- ម្សៅឆា ១/២ ស្លាបព្រា លាយជាមួយ ទឹកក្តៅឧណ្ហ៍ៗ ២ ស្លាបព្រា
- ស្ករស ១ ស្លាបព្រា
- ប្រេងល្ង

រៀបចំសំរាប់មនុស្ស : ២ នាក់
បរិភោគក្នុង: ឆា ១.៥ ពែង និងបាយ ១ ពែង

**ការរៀបចំ :**

លាងខាត់ណា ហើយកាត់ធាងចេញពី ។ ស្រុះដើមខាត់ណាជាមួយទឹកក្តៅក្នុងរយ:ពេលពីរ (២) នាទីទាល់តែពណ៌បៃតងស្រស់ បន្ទាប់មកស្រង់ដើមខាត់ណាចេញ ហើយត្រាំក្នុងទឹកកក ។

ប្រើប្រេងកម្លោចខ្ទឹមសឲ្យពណ៌ពងក្រឡាត ។ នៅពេលដែលខ្ទឹមសកំពុងតែកម្លោច, លាយទឹកខ្យងជាមួយម្សៅឆា និងទឹកសុទ្ធ ។ ចាក់ខាត់ណាចូលជាមួយខ្ទឹមសកម្លោចនោះ បន្ទាប់មកចាក់ទឹកខ្យងលាយជាមួយម្សៅឆានិងទឹកពីលើ ហើយប្រែចុះប្រែឡើង ។ ដាក់ស្ករចូល ហើយបន្តប្រែចុះប្រែឡើង ។ ចំអិនប្រហែល ៣នាទីថែមទៀតទាល់តែខាត់ណាទន់ល្មម ។

ដើម្បីរៀបចំញាំ : យើងចាក់នៅក្នុងចាន ចាក់ទឹកឆាពីលើ ហើយចាក់រោយទឹកប្រេងល្ងពីលើ ។

បរិភោគជាមួយ: បាយអង្ករសំរូប ២ ពែង

**កំណត់សំគាល់អាហារូបត្ថម្ភ**

- បន្ថយជាតិសូឌីយ៉ូម (ប្រើទឹកខ្យងតែ ១/២ នៃចំនួនប្រើធម្មតា)
- ប្រើប្រេងល្អ (ប្រេងកាណូឡា ឬអូលីវ)
- បង្កើនការប្រើជាតិកាបូអ៊ីដ្រាតសរសៃ កាត់បន្ថយការប្រើសារធាតុសម្បូណ៍ដោយកាឡូរី



## Asian Broccoli Stir Fry

*Ingredients/ Shopping list*

- 2 pounds Asian broccoli (about 5 cups raw)
- 1½ tablespoons canola oil
- 1 clove garlic, coarsely chopped
- 1½ tablespoons oyster sauce
- ½ tablespoon cornstarch, dissolved in 2 tablespoons warm water
- 1 teaspoon sugar
- Sesame oil

Serves 2
Serving size: 1½ cups vegetables, 1 cup cooked brown rice

### Preparation

Wash the broccoli, and separate the side stalks from the center stalks. Place the stalks in boiling water for about 2 minutes until they turn bright green, then drain and place in ice water.

Brown the garlic in the oil. While the garlic is cooking, mix the oyster sauce with the cornstarch and water. Add the broccoli to the garlic, then pour the oyster sauce, cornstarch, and water over the top, and toss to mix. Add the sugar and continue to toss. Cook about 3 minutes more until the broccoli starts to soften.

To serve, place on a plate, pour the cooking liquid over the stalks, and shake sesame oil on top.

### Serve with

- 2 cups cooked brown rice

### Nutrition Notes

- Reduced sodium (less oyster sauce)
- Increased fiber/reduced simple carbohydrate (brown rice instead of white rice)



## ឆាត្រកួនសាច់មាន់

### គ្រឿងផ្សំ

- ត្រកួន ១ បាច់ធំ (១.៥ ផោន)
- ប្រេង កាណូឡា ១ ស្លាព្រាកន្លះ
- ខ្ទឹមសចិញ្ច្រាំ ១ កំពឹស
- ទឹកខ្យង ១/៤ ស្លាបព្រា
- ម្សៅឆា ១/២ ស្លាបព្រា លាយជាមួយទឹកក្តៅ ឧណ្ហ៍ៗ
២ ស្លាបព្រាស្ករស ១ ស្លាបព្រា
- សាច់ទ្រូងមាន់ ៦ អោន្ស៍ ហាន់ស្តើងៗ
- ទឹក ១/២ កែវ

រៀបចំសំរាប់មនុស្ស : ២ នាក់
បរិមាណបរិភោគ : បន្លែ និងសាច់ ១.៥ ពែង បាយ ១ ពែង

**ការរៀបចំ :**

លាងត្រកួនឲ្យស្អាត ហើយកាត់គល់ចោលប្រហែលប្រវែង ៤-៥ អិន្ឆ៍ ។ ហាន់សាច់មាន់ជាដុំៗប៉ិន ១/៤ អិន្ឆ៍ ឬជាបន្ទះស្តើងតូចៗល្មម, ហើយត្រឡាក់ជាមួយទឹកស៊ីអ៊ីវ ។ ប្រើប្រេងកម្លោចខ្ទឹមស ។ នៅពេលដែលខ្ទឹមសកំពុងតែកម្លោច លាយទឹកខ្យងជាមួយម្សៅឆា និងទឹក ។ ដាក់សាច់មាន់ចូលជាមួយខ្ទឹមសដែលបានកម្លោចរួចហើយៗចំអិនប្រហែល ៥ នាទី ទាល់តែសាច់មាន់ឆ្អិន ល្អ ។ ចាក់ត្រកួនចូល បន្ទាប់មកក៏ចាក់ទឹកខ្យងដែល លាយ-ជាមួយម្សៅឆា និងទឹកនោះពីលើ ហើយប្រែចុះប្រែឡើងដើម្បីច្របល់គ្នា ។ ដាក់ស្ករចូល ហើយបន្តប្រែចុះប្រែឡើង ។ ចាក់ទឹកកន្លះពែងចូល ហើយចំអិនប្រហែល ២-៣ នាទីទៀត ទាល់តែសន្លឹកត្រកួនទន់ស្រពោន ។

ដើម្បីរៀបចំញាំ : ចាក់ចូលក្នុងចាន, ចាក់ទឹកឆាពីលើត្រកួន ។

បរិភោគជាមួយ : បាយអង្ករសំរូប ២ ពែង

**កំណត់សំគាល់អាហារូបត្ថម្ភ**

- បន្ថយជាតិសូឌីយ៉ូម (ប្រើទឹកខ្យងតិច)
- បន្ថយជាតិខ្លាញ់ឆ្អែត និងជាតិកូលេស្ទ័រោល (ប្រើសាច់ទ្រូងមាន់គ្មានស្បែកជំនួសសាច់គោ ឬសាច់ជ្រូក)
- បង្កើនការប្រើសារធាតុសរសៃ / កាត់បន្ថយការជាតិកាបូអ៊ីដ្រាតធម្មតា (ញាំបាយសំរូបជំនួសបាយសរិត)



## Asian Watercress Stir Fry with Chicken

*Ingredients/ Shopping list*

- 1 large bunch Asian watercress (about 5-6 cups or 1½ pounds)
- 6 ounces boneless skinless chicken breast, sliced thinly
- ¼ teaspoon sweet soy sauce
- 1½ tablespoons canola oil
- 1 clove garlic, coarsely chopped
- 1½ tablespoons oyster sauce
- ½ tablespoon cornstarch, dissolved in 2 tablespoons warm water
- 1 teaspoon sugar
- ½ cup water

Serves 2
Serving size: 1½ cups vegetables and meat, 1 cup cooked brown rice

### Preparation

Wash the watercress well and cut off thick ends about 4-5 inches from end.

Slice the chicken into ¼ inch slices, and coat with the sweet soy sauce.

Brown the garlic in the oil. While the garlic is cooking, mix the oyster sauce with the cornstarch and water. Add the chicken to the garlic, and cook about 5 minutes, until the chicken is cooked through. Add the watercress, then pour the oyster sauce, cornstarch, and water over the top, and toss to mix. Add the sugar and continue to toss. Add the ½ cup water, and cook about 2-3 minutes more, until the watercress leaves are wilted.

To serve, place on a plate and pour the cooking liquid over the watercress and chicken mixture.

ពលេខក្រោយ




# ប្រធានាធិបតី អូបាម៉ា
# ប្រយុទ្ធដើម្បី
# ប្រជាជនអាស៊ាន អាមេរិកាំង
# និងគ្រួសារអ្នកនៅប្រជុំកោះនៃមហាសាគរ ប៉ាស៊ីហ្វិក



▪ អូបាម៉ា បានពង្រីកការទទួលជំនួយ Head start នឹង Early Head Start ទៅដល់ក្មេងចំនួនបន្ថែម៦៤.០០០នាក់ ហើយក្មេងអាស៊ានជិត២៨,៥០០នាក់ទៀត និងចូលកម្មវិធីអប់រំក្មេងក៏រិតដំបូង តាមរយៈ Head Start នេះ ។

▪អូបាម៉ា បានបន្ថែមថវិកាលើស២ដង សម្រាប់ឧបត្ថម្ភ Pell Grants នាឆ្នាំ២០០០នោះធ្វើឱ្យ៤០,០០០ចំនួន Pell Grants និងឱ្យនិស្សិតអាស៊ានទាំងអស់អាចសុំបាន ។

▪ អូបាម៉ា នឹងក្រុម Democrats នៅសភាបានធ្វើការកាត់តាក់ ដើម្បីម្ចាស់ពាណិជ្ជកម្មខ្នាតតូច ១៨ ដង នឹងចុះហត្ថលេខាលើច្បាប់មិនយកពន្ធ២០០ប៊ុលិយ៉ុងដុល្លា នោះបានជួយពង្រីកកម្លាំងពាណិជ្ជកម្ម នឹងបង្កើតការងារ ហើយការកាត់តាត់នេះ បានផ្តល់ជាលទ្ធផលដល់ពាណិជ្ជកម្មជនអាស៊ានចំនួន១,៥លាន ។

▪ អូបាម៉ា នឹង Democrat រៀបចំឱ្យមេឌីឃែ អាចងាយយកបាន ហើយនឹងបន្ត អាយុរបស់មេឌីឃែ នេះ ។ ច្បាប់ The Affordabee Care Act. នឹងបញ្ចប់ការចេញប្រាក់ផ្ទាល់ខ្លួននោឆ្នាំ២០២០ តែមកដល់ឥឡូវនេះ ច្បាប់នោះបានជួយដល់មនុស្សចាស់ចំនួន៥,២លាននាក់ហើយ ហើយនឹងជួយអ្នកពិការឱ្យសន្សំបាន ៣,៧ លានដុល្លារ លើការទិញថ្នាំទៀត ។

▪ អូបាម៉ា បានប្រយុទ្ធ ដើម្បីគ្រួសារថ្នាក់កណ្តាល ដោយវិធីកាត់បន្ថយពន្ធសម្រាប់គ្រួសារអាស៊ាន នឹងពាណិជ្ជករអាស៊ី បានតម្លើងកាតក្រេឌីតសម្រាប់កុមារបាន៥លានគ្រួសារ-កាត់បន្ថយតាក់បៀវត្ស លើអ្នកធ្វើការជាតិអាស៊ី៧,៦លាននាក់-រក្សាឱ្យមានមេឌីឃែសម្រាប់ចាស់ៗអាស៊ី ៕

**សូមអញ្ជើញទៅបោះឆ្នោត ខែវិច្ឆិកា ថ្ងៃទី០៦_ថ្ងៃអង្គារ**
**ធ្វើឱ្យសម្លេងលោកអ្នកបានត្រូវគេឮ**



## VOTE ON NOVEMBER 6TH, TUESDAY

MAKE YOUR VOICES BE HEARD









Paid for by America's Opportunity Fund and not authorized by any candidate or candidate's committee.
AOF mission is to support federal and statewide candidates and elected officials who represent the interests of communities of color, and who inspire participation in government for the benefit of all Americans.

# ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បត្តិ ទី១៨ ខែតុលា ឆ្នាំ២០១២

## ប្រជាពលរដ្ឋខ្មែរគ្រប់រូបចងចាំជានិច្ចចំពោះអតីតព្រះមហាក្សត្រ

**ខេមបូឌា ដេលី**

កាលពីនៅក្មេងស្រីអាយុ១០ឆ្នាំក្នុងទសវត្សរ៍ឆ្នាំ១៩៥០ព្រាំពុំបានឃើញសម្តេចឪយាងទៅមករ ពេលធ្វើព្រះរាជដំណើរបំពេញទស្សនកិច្ចនៅខេត្តកណ្តាលដោយចែកព្រះរាជអំណោយជាក្រណាត់សំពត់ ដូចដែលព្រះអង្គធ្លាប់ធ្វើជារឿយៗដល់ប្រជាពលរដ្ឋដែលឈរតម្រង់ជួរនៅតាមដងផ្លូវស្វាគមន៍ព្រះអង្គ។

ឪពុករបស់នាងពុំដែលធ្វើដំណើរតាមផ្លូវជាតិលេខ៤ ទៅនិងមកពីភ្នំពេញជាអ្នកបើកបររថយន្តក្រុងម្នាក់ បាននិយាយប្រាប់អ្នកស្រីអំពីលំនៅដ្ឋាន ដែលព្រះមហាក្សត្រយាងសាងសង់ឱ្យស្ត្រីមេម៉ាយ និងប្រជាជនក្រីក្រ។

អ្នកស្រីបានឈរមើលបញ្ចសាពណ៌ប្រាក់លាយមាសភ្លឺផ្លេករបស់ព្រះវីរក្សត្រនរោត្តម សីហនុ ដែលបានយាងចូលទីវង្គតដោយសារគាំងបេះដូងនៅទីក្រុងប៉េកាំងកាលពីថ្ងៃច័ន្ទ ឆ្លងកាត់ស្ពានវត្តបទុមតាមផ្លូវពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញសំដៅទៅព្រះរាជវាំង ជាទីដែលព្រះបរមសពត្រូវតម្កល់រយៈពេល៣ខែ ។

អ្នកស្រី ពុំ ដែល ពេលនេះមានអយុ៦៥ ឆ្នាំ បានចំណាយពេលធ្វើដំណើរទាំងយប់តាមរថយន្តក្រុងមួយគ្រឿងពីទីក្រុងប៉ោយប៉ែត ដើម្បីមកមើលសម្តេចព្រះនរោត្តម សីហនុ ជាលើកចុងក្រោយ ។

អ្នកស្រីមានប្រសាសន៍ថា "ពេលនេះគ្មានម្លប់សម្រាប់ប្រជាពលរដ្ឋទៀតទេ"។

ចាប់តាំងពីឡើងគ្រោងរាជក្នុងឆ្នាំ១៩៤១ ដំណើរជីវិតដ៏ច្របូកច្របល់របស់ព្រះបរមសពព្រះមហាវីរក្សត គឺដូចជាស្ថានភាពប្រទេសព្រះអង្គ ដូចជាការទទួលបានឯករាជ្យក្នុងឆ្នាំ ១៩៥៣ ការដឹកនាំរដ្ឋាភិបាលមួយដែលមានការរីកចំរើន ប៉ុន្តែមានភាពផ្តាច់ការ រហូតដល់កើតរដ្ឋប្រហារឆ្នាំ១៩៧០ ចងសម្ព័ន្ធភាពជាមួយអតីតសត្រូវរបស់ព្រះអង្គ គឺខ្មែរក្រហម និងឡើងគ្រងរាជ្យឡើងវិញក្នុងទសវត្សរ៍១៩៩០ ដើម្បីជួយនាំមកនូវស្ថិរភាពដល់នយោបាយជាតិ ដែលមានការបែកបាក់គ្នា ។

ប៉ុន្តែក្នុងចំណោមអ្នកកាន់ទុក្ខរាប់សែនអ្នកដែលឈរជាជួរតាមផ្លូវពេលព្រះអង្គយាងចុងក្រោយមកពីអាកាសយានដ្ឋានទៅកាន់ព្រះបរមរាជវាំងនោះអ្វីៗបានរលាយបាត់អស់ហើយ និងគុណវិបត្តិនានាក៏បានបាត់បង់អស់ដែរ។ តាំងពីក្មេងដល់ចាស់ **តទៅទំព័រទី ៩**

## ការយាងចូលទិវង្គតរបស់សម្តេចឪ គឺការបាត់បង់មហាវីរបុរសជាតិ

**ខេមបូឌាដេលី**

ព្រះបរមសពព្រះករុណាព្រះបាទសម្តេចនរោត្តម សីហនុ ព្រះមហាវីរក្សត្រព្រះវរាជបិតាជាតិខ្មែរ បានយាងនិវត្តជាលើកចុងក្រោយមកកាន់ប្រទេសកម្ពុជា ជាទីស្រឡាញ់របស់ព្រះអង្គវិញ ដោយមានការចាំដង្ហែពីប្រជាពលរដ្ឋប្រមាណ១លាននាក់ ដែលបានឈរអមយ៉ាងស្រងូតស្រងាត់តាមដងមហាវិថី ដើម្បីគោរពព្រះបរមសពព្រះវីរក្សត្រដ៏ជាទីស្រឡាញ់បំផុតរបស់ប្រជាជនកម្ពុជា ។

ប្រជាពលរដ្ឋខ្មែរគ្រប់វ័យបានឈរយ៉ាងស្រងូតស្រងាត់អមតាមដងវិថី ខណៈព្រះបរមសពសម្តេចឪដែលជាក្សត្រមួយអង្គបានទាមទារឯករាជ្យមកជូនប្រទេសជាតិរបស់ព្រះអង្គក្នុងឆ្នាំ១៩៥៣ត្រូវបានដង្ហែទៅកាន់ព្រះបរមរាជវាំង ហើយព្រះបរមសពរបស់ព្រះអង្គ នឹងត្រូវតម្កលនៅទីនោះយ៉ាងតិចណាស់រយៈពេល៣ខែ ។

ព្រះបាទសម្តេចនរោត្តម សីហនុ បានយាងចូលវង្គតដោយសារគាំងបេះដូងនៅក្នុងជន្មាយុ៨៩ព្រះវស្សា នៅវេលាម៉ោង១និង២០នាទីរំលងអាធ្រាត្រកាលពីថ្ងៃច័ន្ទក្នុងទីក្រុងប៉េកាំង។

ក្នុងនាមជាប្រជាពលរដ្ឋខ្មែរ ដែលបាននាំគ្នាចេញមកតាមដងមហាវិថីយ៉ាងច្រើនហួសពីការស្មានដើម្បីចូលរួមព្រះរាជពិធីដង្ហែព្រះបរមសពព្រះ-ករុណា ព្រះបាទសម្តេចនរោត្តមសីហនុព្រះមហាវីរក្សត្រ ព្រះរាជវរាជបិតាជាតិខ្មែរប្រជាពលរដ្ឋភាគច្រើនមិនដែលធ្លាប់ជួបប្រទះការយាងចូលទីវង្គតរបស់ព្រះមហាក្សត្រនោះ បានមកប្រមូផ្តុំគ្នាដើម្បីចូលរួមកាន់មរណទុក្ខ ចំពោះព្រះបរមសពព្រះបាទសម្តេចនរោត្តមសីហនុ ។

សាលារាជធានីភ្នំពេញបានមលើកឡើងថាខ្លួនបានរៀបចំសម្រាប់អ្នកចូលរួមប្រមាណមួយសែននាក់ ប៉ុន្តែកាលពីម្សិលមិញ ចំនួនអ្នកចូលរួមកាន់មរណទុក្ខបានកើនឡើង១០ដងលើសពីការប៉ាន់ស្មានរបស់មន្ត្រីសាលារាជធានីភ្នំពេញ ។

លោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលារាជធានីភ្នំពេញបានឱ្យដឹងថាថា "មន្ត្រីនគរបាលបានរាយការណ៍ថា មានប្រជាពលរដ្ឋជិត១លាននាក់បានចូលរួមដង្ហែព្រះបរមសព **តទៅទំព័រទី ១៧**

## One Million Line the Streets in Final Farewell to King Father

By Eang Mengleng And Simon Lewis
**THE CAMBODIA DAILY**

The late king father Norodom Sihanouk made his final journey back to Cambodia yesterday tobe greeted by an estimated 1 million people who lined the streets in reverential silence the witness the return of the country´s much-loved monarch.

Cambodians of all ages stood silenly on the roadside as the King Father, and the man who earned the country its independence in 1953, was brought to the Royal Palace, where his body will lie in state for at least thrre months.

Norodom Sihanouk died from heart failure at the age of 89 in the early hours fo Monday mornig in Beijing.

Turnout the witness the royal procession exceeded expecatations of Cambodians the majority of whom have never lived through the death of a monarch had their chance to collectively mourn Noro dom Sihanouk.

The Phnom Penh Municipality had said it was preparing for 100, 000 attendees, but estimated made by municipal officials yesterday were 10 times tha amount.

"Police reported that nearly 1 million people attended to welcome the King Father´s body in the streets between the airport and the Royal Palace," City hall spokesman Ling Dimanch said.

At 2:50 p.m., an Air China jum bo jet touched down at Phnom Penh International Airport, begin ning a formal and elaborate cere mony tha went on until the early evening.

Gathered on the tarmac to welcome the aircraft and the return of the royal family were government officials dressed in white tunics with gold buttons, senior members fo the Buddhist clergy, royals and foreign diplomats.

The late Norodom Sihanouk´s wife, Queen Mother Monineath, emerged solemnly from the plane and was helped down the steps by her son, King Norodom Sihamoni. The Queen Mother and King Siha moni were followd closely by Prime Minister Hun Sen and a host of government officials and royals. A monk´s incantations blared through the airport´s loudspeaker system.

At the rear of the aircraft, Royal Palace guards carried out the coffin of Norodom Sihanouk, where it was aborned with golden panels and a jasmine covering, to form a larger, ornate sarcophagus. A blue flag bearing the Royal Arms fo Cambodia was laid on top.

At the casket was lowered from the plane, it was greeted by a trum pet call and a salute from a troop of riflemen. The guards then lifted the casket with difficulty onto a processional carriage in the shape of a golden mythical bird. After a pause, traditional musicians began to play on another carriage and the procession started on its route to the palace.

"The monks pray for the King Father and wish that he ascends to paradise," said Sao Chanthol, chief monk at Phnom Penh´s Wat Lanka, prior to the King Father´s body being hoisted onto the funeral carriage. Before the King Father´s arrival, the venerable Sao Chanthol said monks had been praying for the King Father since they heard of his death.

Kandal province resident Phorng Phaly, 66, quietly spoke at the airport of her love for the late King Father as he stood withe others holding pictures of Norodom Sihanouk.

"The King worked hard for us and demanded that we get Preah Vihear from Thailand," she said, in reference to the case the King initiated at the International Court of Justice that awarded Cambodia the border-hugging temple in 1962.

Russian Confederation Boulevard from the airport to the center of Phnom Penh was lined with people, standing four or five deep in places.

Spectators were almost all dressed in white, the traditional mourning color, and wore black ribbons, or simple pieces fo black cloth, pinned to their clothes. People clasped their hands in prayer, some holding the national flag or lotus flowers, some with tears in their eyes. All looked on in silences as the casket passed by.

The King Father´s body took just over an hour to reach the Royal Palace at about 5:20 p.m. For the thousands of people who waited for hours, it was a welcome but equally bitter sight.

The air around the palace was filled with a collective cry as the carriage moved along the last stretch of the 10-km journey.

Onlookers, who remainded mostly seated, fell silent as the procession passed on toward the palace, where several hundred monks had patiently waited since midday. The monks began chanting as the carriage turned in to the palace gates. It was followd by King Sihamoni and Mr. Hun Sen, whose cars drove up to the gates.

The King Father´s son, Prince Norodom Ranariddh, got out of his car further down th boulevard walked with his own son, greeting onlookers as he did, to the palace.

As the King´s body entered the palace grounds, the yellow bulbs that line the palace walls lit up. The scrum around the gates began to dissipate and move toward the late King´s giant portrait.

The King Father´s body will lie in state for at least three months and will then be cremated, most likely in a pyre on Veal Mean, the gardens in front of the National Museum.

Wiping away her tears, Pheoun Vann, 40, from Kandal province reminisced fo the days under King Noro dom Sihanouk.

"Now that he has passed away, I have no feeling or trust, not even to vote," she said. "It is getting harder to live. The people are becoming poorer. During the King Father´s days it wasn´t this hard. We lived very happily. Everything was much cheaper."

*(Additional reporting by Lauren Crothers and Kaing Menghun)*



# ទស្សនៈមតិជុំវិញការសោយទិវង្គត
# អតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ វ្ម័ន







**ដោយ : ម៉ម យ៉ឹន**

●●●ក្នុងនាមរូបខ្ញុំជាជាតិខ្មែរ ខ្ញុំធ្លាប់បានរស់នៅឆ្លងកាត់តាមរយៈការគ្រប់គ្រងដឹកនាំរបស់ព្រះមហាក្សត្រព្រះនាមព្រះបាទសម្តេចនរោត្តម សីហនុ ដែលព្រះអង្គបានឡើងសោយរាជ្យសម្បត្តិតាំងពីឆ្នាំ១៨៤១ បន្តរាជ្យពីព្រះបាទស៊ីសុវត្ថិ មុនីវង្ស នោះមក។

ខ្ញុំសូមសំដែងនូវសេចក្តីរំយោគក្រៀមក្រំសោកស្តាយព្រះអង្គដែលបានសោយទីវង្គតទៅ កាលពីថ្ងៃទី១៥ខែតុលាឆ្នាំ២០១២ក្នុងព្រះជន្មាយុ៩០ព្រះវស្សានៅក្រុងប៉េកាំងប្រទេសចិនប្រជាមានិត។

បន្ទាប់ពីបានទទួលដំណឹងដ៏ក្រៀមក្រំនេះ រូបខ្ញុំមានចំណាប់អារម្មណ៍យ៉ាងរំជួលចិត្តខ្លាំងណាស់ ទៅដល់អតីតកាលរបស់ព្រះអង្គចំពោះព្រះរាជបូជនីយកិច្ចធំៗសំខាន់ៗចំពោះប្រទេសជាតិខ្មែរ រហូតដល់បណ្តាមហាជនជាតិខ្មែរ បានប្រសិទ្ធ

**តទៅទំព័រ ១៧**


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

# មតិមិត្តអ្នកអាន

## Dan Peou

ខ្ញុំគិតពេញមួយអាទិត្យពីរឿងសម្ដេច សីហនុ ចូលទិវង្គត ខ្ញុំគិតថា ជាឱកាសអាចជួយព្យាបាលខ្មែរពីបាបកម្មដែលអាចប្រព្រឹត្តពី៣០ឆ្នាំមកហើយ ។ តែដល់ខ្ញុំបានឮប្រតិកម្មពីខ្មែរនៅបរទេស និងខ្មែរនៅស្រុកខ្មែរ នាពេលបន្ទាប់មក ខ្ញុំបែរជាមានអារម្មណ៍លាយឡំច្រើនពីព្រឹត្តិការណ៍នោះ ។ ខ្ញុំគិតថា ខ្មែរនៅស្រុកខ្មែរយល់ថា ខ្មែរនៅបរទេសស្អប់ស្ដេច ! ខ្ញុំមិនជឿថា ដូច្នោះទេ ខ្មែរនៅបរទេសគ្រាន់តែមិនពេញនឹងការដឹកនាំរបស់សម្ដេច សម្រាប់ខ្ញុំស្ដេចបានប្រព្រឹត្តឆ្គាំឆ្គងចំពោះពលរដ្ឋឯងដែលបានភាសខ្លួនបន្ទាប់ពីសម័យខ្មែរក្រហម... ខ្ញុំមិនស្អប់ព្រះអង្គទេ ហើយខ្ញុំបានរៀនអត់ទោសឱ្យព្រះអង្គ ខ្ញុំនឹងផ្ដល់ការចូលរួមមរណទុក្ខដ៏ជ្រាលជ្រៅទៅពលរដ្ឋខ្មែរ ដែលបានបាត់បង់ស្ដេចរបស់ខ្លួន ។

During this entire week, I can't help but thinking about the passing of the king of Cambodia. I thought that it might be good for the country to starting healing from the atrocity that occurred over thirty years ago. As time goes by and as I pay more attention to the reactions from both Khmer people in Srok Khmer and Khmer people living abroad, I am starting to have a mixed feeling toward what is happening.

First of all, I think that most Khmer in Srok Khmer think that all Khmer living abroad hate the king. I do not believe it is the case. I believe that most Khmer people living abroad are disappointed and resentful of his leadership. To me personally, I thought the king had made many mistakes, especially to his people who sought refuge outside of Cambodia after the Khmer Rouge era.

After the Khmer Rouge Regime was defeated, did he think about his people in the country as well as the ones forced to live abroad? I believe that Khmer people living abroad are still very resentful that he had made no effort to reach out to us. We felt that we were no longer part of his people, though we desperately desired to hear from him.

On the other hand, I have developed strong friendship with many people in Srok Khmer, some of whom I have a great deal of respect for. I am noticing that everyone is mourning the loss of the king. Some have proclaimed that he was the greatest king of all time. I thought to myself that maybe he had changed and he did care for his people in the country. With this, I am starting to change my perspectives toward him. I don't hate him and I have even learned to forgive him. I am starting to think of all Khmer people everywhere. We are Khmer by birth and nothing will change that.

In closing, I would like to offer my deepest condolences to the people in Srok Khmer for the loss of their king. May he rest in peace and taking comfort from all the love his people are showing. And also, to pray for the two million souls that perished tragically during the Khmer Rouge era. They will never be forgotten from our memories.

## Sengly Kong

**ខ្លួនខ្ញុំផ្ទាល់យល់ថា កម្ពុជា ដែលជាប្រជាជាតិមួយ បានបាត់បង់ស្ដេចដ៏ល្អមួយអង្គរបស់ខ្លួន...**

I personally feel that Cambodia as a nation loses a great king, an unparalelled statesman, an astute world known politician, a great source of wisdom, a great role model of leadership, and a great protector king of the 20th century. I hope that history will judge him and his contribution to his kingdom and his people as fairly and accurately as he so deserves. My condolences to queen mother and our current king!

## Visal Ross

**...នេះជាលើកដំបូងហើយ ដែលខ្ញុំនិយាយពី សីហនុ តាំងពីលោកសុគតមក -ព្រះអង្គពុំមែនជាវីរបុរសរបស់ខ្ញុំទេ -ខ្ញុំចាំថា កាលពីនៅកុមារគេរកឃើញខ្ញុំពីគំនរខ្មោចនៅតាមផ្លូវភៀសខ្លួនទៅកាន់ប្រទេសថៃឆ្នាំ១៩៧៩ -ឪពុកម្ដាយខ្ញុំស្លាប់ជាមួយគ្រួសារទាំងមូល មុននឹងខ្ញុំចាំបានថា ពួកគាត់មានមុខមាត់យ៉ាងម៉េចនោះ -ហេតុនេះខ្ញុំមិនអាចទទួលស្គាល់ថា សីហនុ អស្ចារ្យ ឬមានវីរៈភាព ដូចដែលមនុស្សជាច្រើនលើកតម្កើងបុណ្យសពនោះទេ ។**

My interpretation, no denial, other than that he have been known for a playboy prince with hundreds of mistresses he was a disaster leader who never responsible for his own faults. In his false moved in affiliating to the Ho Chi Minh Trail, he took steps to repair relations with the United States.

He turned a blind eye when the Nixon administration undertook a secret bombing campaign in 1969 inside Cambodia. Later overthrow in 1970 by Sirik Matak and Lon Nol, then allied himself with the Khmer Rouge and helped bring Pol Pot to power in 1975 which nearly destroyed the country. He served the first year of the Khmer Rouge rule as head of state until he was placed under house arrest in the Royal Palace. Later he was rescued when the Vietnamese invaded Cambodia and overthrew the Khmer Rouge in 1979. But rather than turn against Pol Pot, he went to the United Nations and defended him.

In the end, sided with Hun Sen and brought him to power even that he lost the United Nations sponsored election in 1993. With that said, in my opinion, he doesn't deserve any better respect, dead or alive. He was one of the important figure for the devastations and destructions of Cambodia and why the nation still rules by a bunch of Khmer Rouge comrades today.

Undoubtedly, he lives a lavish life subsidized by the Chinese and North Korean government at his opulent palaces in North Korea and China whiles our people suffer. Sorry folks, I think I hold my thoughts long enough. This is the first time I says something about Sihanouk since his death. He is no hero to me. I was found when I was a toddler among many dead people along the way migrating to Thailand in late 1979. I lost both of my parents and the entire family before I could even remember how they look like. For this, I can't utterly agree on the concept of how great and heroic Sihanouk was as many people stated in honor of his passing.



# ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី១៨ ខែតុលា ឆ្នាំ២០១២

តមកពីទំព័រទី ៦

## ប្រជាពលរដ្ឋខ្មែរគ្រប់រូបចងចាំជានិច្ចចំពោះ...

អ្វីដែលកើតមាននោះ គឺការរៀបរាប់ជាធម្មតាអំពីឆាកជីវិតរបស់ព្រះមហាវីរក្សត្រនរោត្តមសីហនុ ជាវីរជនស្នេហាជាតិមួយអង្គដែលបានផ្តើមឯករាជ្យជូនជាតិការពារឯករាជ្យពីប្រទេសជិតខាង និងនាំមកនូវសន្តិភាព ។

លោកយាយ ពិន ឡន អាយុ៧១ឆ្នាំ ដែលកាន់ធូបមួយដើមបួងសួងដល់សម្តេចឪ នៅព្រះអង្គដងកើ បានមានប្រសាសន៍ថា "ខ្ញុំចាំព្រះអង្គបានតាំងពីព្រះអង្គនៅក្មេង។ ព្រះអង្គតែងតែនាំសន្តិភាពជូនប្រជាជនទាំងមូល" ។

លោកយាយមានប្រសាសន៍ថា "កាលព្រះអង្គនៅមេដឹកនាំ ព្រះអង្គតែងតែការពារទឹកដី ហើយជនបទបរទេសមិនដែលយកទឹកដីរបស់យើងទេ" ។

លោកតា ណៅ អួន អាយុ៧១ ឆ្នាំនធ្វើដំណើរពីខេត្តព្រៃវែងនៅព្រឹកព្រហាមមកឈប់នៅក្រោមម្លប់ដើមឈើនៅទល់មុខក្លោងទ្វារធំព្រះបរមរាជវាំង។ លោកតាចងចាំយ៉ាងច្បាស់ពីអតីតព្រះមហាក្សត្រ ដែលបានយកប្រាសាទព្រះវិហារពីប្រទេសថៃមកវិញក្នុងឆ្នាំ១៩៦២ ។

ក្នុងរឿងក្តីរបស់ព្រះមហាវីរក្សត្រ តុលាការយុត្តិធម៌អន្តរជាតិបានប្រគល់ឱ្យកម្ពុជាវិញនូវប្រាសាទដែលនៅជាប់ព្រំដែន ហើយនៅពេលនោះមានការជំទាស់យ៉ាងខ្លាំងភាគីថៃ ។ ជាមួយដីមួយកន្លែងនៅជិតប្រាសាទនោះដែលនៅតែមានការតវ៉ាយ៉ាងក្តៅគគុក និងនៅតែមានជម្លោះជាមួយប្រទេសថៃនោះ ប្រាសាទព្រះវិហារទាសតវត្សរ៍ទី១១នេះ នៅតែជានិមិត្តរូបដ៏ធំធេងនៃមោទភាពជាតិសម្រាប់ប្រជាពលរដ្ឋខ្មែរ ។

លោកតា អួន មានប្រសាសន៍ថា "ព្រះមហាវីរក្សត្របានយកប្រាសាទព្រះវិហារមកវិញ ។ បើទោះវាជាប្រាសាទតូចមួយក៏ដោយក៏វាជាស្នាដៃរបស់ខ្មែរដែរ ។ ប្រាសាទនេះត្រូវបានកសាងឡើងដោយប្រជាពលរដ្ឋខ្មែរ "។

លោក យាយ ផេង លីម អាយុ៧៨ឆ្នាំបានជិះរថយន្តតាក់ស៊ីពីខេត្តកំពង់ចាមជាមួយចៅស្រីរបស់គាត់ដើម្បីមកចូលរួមជាមួយប្រជាជនផ្សេងទៀតដោយរង់ចាំការដង្ហែព្រះបរមសពតាមវិថីព្រះនរោត្តម។ ពេលបឺតទឹកក្រូចមួយថង់តូចលោកយាយចង់ចាំពីសម្តេចឪ ពេលព្រះអង្គឡើងគ្រងរាជបានតិចជាងពេលព្រះអង្គប្រឡូកក្នុងឆាកនយោបាយ ។

ការដាក់រាជលើកដំបូងក្នុងឆ្នាំ១៩៥៥សម្តេចព្រះនរោត្តសីហនុ បានធ្វើជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ដែលទើបទទួលបានឯករាជ្យថ្មីៗ រហូតដល់មានការធ្វើរដ្ឋប្រហារក្នុងសភា ពីសំណាក់ប្រឆាំងគាំទ្រអាមេរិក ។

បើទោះបីជាត្រូវបានរារាំងដោយការគៀបសង្កត់ដោយឃោរឃៅពីពួកប្រឆាំងក៏ដោយក៏ទសវត្សរ៍ឆ្នាំ៥០ និងទសតវត្សរ៍ គឺជាសតវត្សរ៍នៃសន្តិភាពសំបូររុងរឿងដែរ ។

លោកយាយ លីម បានរៀបរាប់ដោយពោលសំដៅដល់ចលនាសង្គមនិយម ដែលព្រះបាទនរោត្តមសីហនុគ្រប់គ្រងថា "ព្រះអង្គជាមេដឹកនាំដ៏ល្អមួយអង្គអំឡុងសង្គមរាស្ត្រនិយម" ។ លោកយាយបន្តថា "នៅពេលនោះប្រជាពលរដ្ឋមានសន្តិភាព" ។

ដែលត្រូវបានបណ្តេញចេញពីអំណាចក្នុងរដ្ឋប្រហារនឹងគង់នៅបែបនិរទេសព្រះកាយសម្តេចព្រះនរោត្តមសីហនុ ចងសម្ព័ន្ធភាពជាមួយខ្មែរក្រហមដោយដឹកនាំចលនាជាតិនិយមមួយដែលបានលើកទឹកចិត្តមនុស្សជាច្រើនឱ្យចូលរួម ដោយសារមានជំនឿថា ពួកអាចទទួលបានរបបរាជានិយមមកវិញ ។

នៅក្នុងក្រុមមនុស្សដែលបានចូលរួមក្នុងពិធីមនុស្សមានវ័យចំណាស់ដែលអាចចង់ចាំបានលើកឡើងថា ពួកគាត់ដឹងតិចឬមិនដឹងសោះអំពីសម័យនោះ ។ អ្នកដែលចង់ចាំបាន គឺចង់ចាំបានយ៉ាងច្បាស់ ។

លោក ចាន់ សំអាន អាយុ៦៦ឆ្នាំ បានមានប្រសាសន៍ថា "ខ្ញុំមិនយល់អំពីគំនិតរបស់ព្រះអង្គទេ ប៉ុន្តែប្រហែលជាព្រះអង្គចូលរួមដើម្បីអាចប្រែក្លាយពីរឿងអាក្រក់ទៅជារឿងល្អ សម្រាប់ប្រជាពលរដ្ឋ" ។

ដូចមនុស្សគ្រប់ៗគ្នា ដែលនៅចាំតែព្រះបាទនរោត្តមសីហនុដែលជាព្រះបិតាឯករាជ្យរបស់កម្ពុជាប៉ុណ្ណោះ។ លោកបន្តថា "ព្រះអង្គគឺជាជនស្នេហាជាតិ ។ ព្រះរំដោះប្រជាជនចេញពីអាណានិគមបារាំង" ។

នៅឆ្ងាយពីផ្លូវដង្ហែព្រះបរមសពនិងព្រះបរមរាជវាំង តំបន់ភាគច្រើននៅរាជធានីមានសភាពស្ងប់ស្ងាត់ជាធម្មតា។ ក៏ប៉ុន្តែអាជីវករនៅផ្សារចាស់ខាងត្បូងវត្តភ្នំ កំពុងតែប្រកបរកស៊ីយ៉ាងមមាញឹកដោយមានដោតទង់ជាតិកម្ពុជា និងដាក់តាំងព្រះឆាយាលក្ខណ៍របស់សម្តេចឪ ។

លោក ខាន់ សុគន្ធ អាយុ៥៧ឆ្នាំលក់ទុងជាតិតូចមួយតម្លៃ៥ពាន់រៀលព្រះឆាយាលក្ខណ៍មានស៊ុំរបស់សម្តេចឪតម្លៃ២ម៉ឺន២ពាន់រៀល។

គាត់បាននិយាយថា ព្រះឆាយាលក្ខណ៍នេះមិនសូវសំខាន់សម្រាប់ខ្លួនគាត់ គឺសម្រាប់កូននិងចៅរបស់គាត់ ។

គាត់បាននិយាយថា "ខ្ញុំចង់រក្សាទុកព្រះឆាយាលក្ខណ៍ក្នុងសម្រាប់ក្មេងជំនាន់ក្រោយដើម្បីចង់ចាំសម្តេចឪ" ។

គាត់បានបន្តថា "ខ្ញុំក្រៀមក្រំណាស់ដែលបាត់បង់សម្តេចឪ។ នៅពេលព្រះនៅមានព្រះជន្មព្រះអង្គតែងតែធ្វើការដើម្បីប្រជាជនខ្មែរ ។ ព្រះអង្គជាវីរបុរសខ្មែរ "៕

## In Mourning, King Father Remembered in Best of Light

By Zsombor Peter And Aun Pheap
**THE CAMBODIA DAILY**

As a girl of 10 in the 1950s, Prum Pum would see the King Father coming and going on visits to Kandal province, passin out tissues as he often did to the crowds that lined his route.

Ms. Pum´s father, who plied National Road 4 to and from Phnom Penh as a bus driver, would tell her of the houses the King and built for windows and the poor.

Yesterday, she watched the shimmering silver-gold casket of the late King Norodom Sihanouk who died of the heart attack in Beij ing Monday pass by Wat Botum Park on its way from Phnom Penh International Airport to the Royal Palace, where it will lie in state for the next three months.

"I feel so sad because we lost our King," said Ms. Pum, who now 65, spent the previous night traveling on a bus from Poipet City to see Norodom Sihanouk one last time.

"Now there is no shape for the people," she said.

Since taking the throne in 1941, the late King´s tumultuous life mirrored his country´s: gaining independence in 1953, heading a prosperous if repressive government until falling to a coup in 1970, allying with his former enemies in the Khmer Rouge, and returning to the throne in the 1990s to help bring stability to fractious national politics.

But among the hundreds of thousands of mourners who lined the route of the King Father´s last journey from the airport to the palace yesterday, all nuance was gone, flaws papered over. From young to old, what emerged was a simpler narrative of Norodom Si hanouk´s life; a national hero who restored the nation´s independence, defended it from greedy neighbors, and brought them peace.

"I remeber the King since he was young; he always brought peace to the people," said Pin Lorn, 71, clutching a single stick of incense for the late King between her palms at Preah Ang Dang Keou, a tiny riverside shrine facing the Royal Palace.

"When he was a leader, he always protected the land and foreigners never took our territory," she said.

Nao Onn, 70, drove in from Prey Veng province in the early morning to stake out a prime spot in the shade across from the main palace gate. He best remembered the late King for winning Preah Vihear temple back from Thailand in 1962.

In a case initiated by the King, the International Court of Justice awarded Cambodia the border-hugging temple that year over Thailand´s stiff objections. With a patch of land next to it still hotly contested, and still fought over with Thailand, the 11th-century Preah Vihear temple remains a potent symbol of national pride for Cambodians.

"The King took Preah Vihear back," Mr. Onn said. "Even though it is a small temple, it is the achievement of the Khmer. It was built by the Khmer people."

Pheng Lim, 78, took a taxi from Kompong Cham province with her granddaughter to join the crowds waiting for the procession along Norodom Boulevard. Between sips from a small bag of neon pink soda, she remembered the late King less for his time on the throne than for his year in politics.

Addicating for the first of two times in 1955, Norodom Sihanouk served as head of state of a newly independence Cambodia until a parliamentary coup staged by pro-U.S. rivals. Though marred by the brutal suppression of dissent, of the political left especially, the 1950s and 1960s were decades of general peace and prosperity.

"He was a good leader during the Sangkum Reastr Niyum," Ms. Lim recalled, referring to the vaguely socialist political movement Norodom Sihanouk governed by. "At that time, the people had peace."

Ousted from power in the coup and living in exile, Norodom Siha nouk allied himself with the Khmer Rouge, leading the movement a facade of nationalism that encouraged many to join in the belief that they could restore the monarchy.

Those in yesterday´s crowds old enough to remember said they knew little or nothing of those days. Those who did remember, put it in the best possible light.

"I don´t understand his mind, but maybe he joined so he could turn a bad thing into a good thing for the people," said Chan Saman, 66.

Like everyone else, he remembered only Norodom Sihanouk, the father of Cambodia´s indepen dence. "He was a patriot," he said. "He liberated the people from French colonialism."

Away from the procession route and palace, much of the city was quieter than usual. But vendors at the Old Market south of Wat Phnom were doing a brisk business in Cambodian flags and the King Father´s framed portraits.

Kann Sokunth, 57, was stocking up on small flags for $1.25 each and a framed portrait of the King Father for $5.50.

The portrait, he said, was less for himself than for his children and grandchildren.

"I want to keep it in the house for the young generation to remember the King Father," he said.

"I am sad for the loss of the King Father. When he was alive, he always worked for the Cambo dian people," he said. "He was the hero of Cambodia."

# ក្លូបូលវិតណេសរាយការណ៍ពីបរិស្ថាននៅកម្ពុជា

(តពីលេខមុន)

### បែងចែកទ្រព្យសម្បត្តិសាធារណៈឱ្យមិត្តជិតស្និទ្ធ និងសាច់ញាតិរបស់អ្នក ដឹកនាំកម្ពុជា

នេះពាក់ព័ន្ធការបែងចែកសម្បទានព្រៃឈើ ដីធ្លី ស្រទាប់រ៉ែ មច្ឆា និងតំបន់កៀរដីណែលស្របកិច្ចព្រមព្រៀង "ផ្លាស់ប្តូរដី" លើអាគារកាន់កាប់ដោយរដ្ឋ ។ ប្រតិបត្តិការជាច្រើនក្នុងចំណោមនេះគឺខុសច្បាប់ ។ អ្នកទទួលប្រយោជន៍គឺជាមហាសេដ្ឋីមួយក្រុមតូច ដែលមានចំណងនយោបាយអាជីវកម្ម ឬគ្រួសារជាមួយមន្ត្រីជាន់ខ្ពស់ ។ ផលប៉ះពាល់ គឺនឹងដាក់ឱ្យទ្រព្យសម្បត្តិសាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលឯកជន ដែលពួកគេជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋមានតែឈ្មោះ ។

ក្នុងការបកស្រាយបង្ហាញពីការត្រួតស៊ីគ្នារវាងនយោបាយ និងអាជីវកម្មនេះ មហាសេដ្ឋីចំនួនប្រាំមួយ ក្នុងចំណោមមហាសេដ្ឋីខ្លាំងបំផុតបច្ចុប្បន្ននេះ ត្រូវបានតែងតាំងជាព្រឹទ្ធសមាជិកសម្រាប់គណបក្សប្រជាជនកម្ពុជារបស់ ហ៊ុន សែន ។ អ្នកទាំងប្រាំមួយនោះ គឺ កុក អាន, គង់ ទ្រីវ, លី យ៉ុងផាត់, ឡៅ ម៉េងឃិន (ដែលស្របជាមួយភរិយារបស់គាត់ យាយភូ គ្រប់គ្រងក្រុមហ៊ុន Pheapimex) ម៉ែន សារុន[១៥] និង មុំង ឫទ្ធិ ។ រូបភាព ១ រៀបរាប់សង្ខេបពីផលប្រយោជន៍ចម្រុះៗរបស់ពួកគេ ។






ឯកសារយោងនៃទិន្នន័យនេះ មានការបកស្រាយនៅក្នុងឧបសម្ព័ន្ធ ១

ព័ត៌មានពីកិច្ចព្រមព្រៀងពាក់ព័ន្ធទ្រព្យសម្បត្តិសាធារណៈ មិនត្រូវបានធ្វើឱ្យអាចទទួលបានដល់ប្រជាជនកម្ពុជា ដែលពួកគេទាំងអស់គ្នាជាម្ចាស់នោះទេ ។ សម្រាប់ពលរដ្ឋធម្មតា ដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធាន ដែលកំពុងត្រូវបានចុះហត្ថលេខាលក់ចេញ ដំបូង ដែលពួកគេឮពីសម្បទានថ្មី ជាញឹកញាប់ គឺជាសម្លេងនៃរណារយន្តកាត់ព្រៃឈើរបស់ពួកគេ ឬម៉ាស៊ីនឈូសពង្រាបដំណាំរបស់ពួកគេ ។

ផលប៉ះពាល់លើមនុស្សភ្លាមៗនៃការច្រៀកយកទ្រព្យសម្បត្តិនេះ គឺបដិសេធសិទ្ធិចេញចូលរបស់ប្រជាជនខ្មែរទៅកាន់ធនធានធម្មជាតិ និងក្នុងករណីខ្លះ បណ្តេញពួកគេចេញពីផ្ទះរបស់ពួកគេ ។ កាន់តែទូលំទូលាយថែមទៀតនោះ ការពុះច្រៀកនេះ កាត់ផ្តាច់ចំណូលពីប្រជាជនទាំងអស់ ដែលអាចទាញយកមកពីការគ្រប់គ្រងប្រកបដោយចីរភាពនូវទំនិញសាធារណៈទាំងនេះ ។ អំពើពុករលួយដែលសម្របសម្រួល




ប័ណ្ណចេញដោយខ្មែរក្រហមឱ្យអ្នកកាប់ឈើប្រតិបត្តិការក្នុងតំបន់ដែលពួកគេបានគ្រប់គ្រង

សម្បទានច្រៀកទ្រព្យសម្បត្តិនេះ ធ្វើឱ្យអន្តរាយដល់ទីតិរដ្ឋ ស្របពេលការបង្កើនទ្រព្យសម្បត្តិរបស់គ្រួសារអ្នកដឹកនាំ ផ្តល់ឱ្យពួកគេនូវអំណាច និងភាពគ្មានទោសដែលកាន់តែកើនឡើង ។ លទ្ធផលចុងក្រោយ គឺថាប្រជាជនខ្មែរដែលក្រីក្ររួចហើយនោះ កាន់តែក្រទៅៗ ហើយឃើញថាកាន់តែពិបាកក្នុងការទាញយកអ្នកគ្រប់គ្រងប្រទេសឱ្យទទួលខុសត្រូវ ។

### អំពើពុករលួយក្នុងស្ថាប័នរដ្ឋាភិបាលដែលបង្កើនទ្រព្យធនមន្ត្រីជាន់ខ្ពស់

ចូនកាលអំពើពុករលួយក្នុងប្រទេសកម្ពុជា ត្រូវបានពណ៌នាតែថាជាយន្តការរស់រាន ដោយមន្ត្រីរាជការដែលមានប្រៀវត្សមិនសមរម្យ ។ ទោះយ៉ាងណាក៏ដោយ ក្នុងស្ថាប័នទាំងនេះ ជាមួយទំហំធំបំផុតសម្រាប់ស្វែងរកថ្លៃឈ្នួល ជាទូទៅ បុគ្គលិកចំណាយសម្រាប់ការងាររបស់ពួកគេ ធ្វើការបង់ប្រាក់ជាប្រចាំដើម្បីរក្សាពួកគេ និងរំពឹងថាបានមកវិញនូវចំណាយទាំងនេះ តាមរយៈអំពើពុករលួយ[២០] ។ ប្រាក់ដែលបានមកតាមរយៈការអនុវត្តអំពើពុករលួយហូរទៅខាងលើតាមរយៈរចនាសម្ព័ន្ធពីរ៉ាមីត ដែលមានការបែងចែកច្រើនបំផុតបង្កើនក្នុងហោប៉ៅរបស់អ្នកទាំងឡាយដែលស្ថិតនៅកម្រិតកំពូលនៃឋានានុក្រម[២១] ។ បន្ទុកនៃអំពើពុករលួយជារៀងរាល់ថ្ងៃក្នុងប្រទេសកម្ពុជា ធ្លាក់ធ្ងន់បំផុតទៅលើអ្នកទាំងឡាយដែលគ្មានអំណាច និងទំនាក់ទំនង ដើម្បីប្រឆាំងតបត ។

តទៅលេខក្រោយ

[iv] "រដ្ឋដែលមានតែឈ្មោះ" គឺជាពាក្យមួយដែលបង្កើតដោយបណ្ឌិតសភា William Reno ដើម្បីរៀបរាប់ពីវិធីដែលរដ្ឋាភិបាលត្រូវអនុម័តដោយប្រមុខរដ្ឋអាហ្វ្រិក ។ លក្ខណៈបង្ហាញពី "រដ្ឋដែលមានតែឈ្មោះ" ទាំងនេះ រួមមាន ការប្រើប្រាស់បណ្តាញក្រៅផ្លូវការ ដើម្បីបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងអនុវត្តអំណាច ធ្វើឱ្យអន្តរាយដោយគិតទុកជាមុនដល់ស្ថាប័នផ្លូវការរបស់រដ្ឋាភិបាល និងបែបបទគ្រប់គ្រងបដិរូបខ្ពស់ដែលមិនអនុវត្តយោងតាមច្បាប់ ។ (William Reno "សេដ្ឋកិច្ចផ្ទុយច្បាប់អំពើហិង្សា និងរដ្ឋក្នុងអាហ្វ្រិក" សារព័ត៌មានកិច្ចការអន្តរជាតិលេខ ៥៣ ឆ្នាំ ២000) ។


# ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្ចៀមធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អិនសួរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



FREE Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 30/04/2012

"EXCLUSIVE OFFER" $55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 30/04/2012

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ប៉ានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com

# ថ្វាយព្រះពរដល់សម្តេចឪ-សម្តេចតា



**ឃើញក្នុងអ៊ីមែល Facebook**

**អាល់ប៊ែរ ឃុត :** អនាគតខ្មែរ ខ្ញុំនៅក្នុងហ្វូងនិស្សិតតាមផ្លូវសហភាពសូវៀតដែលក្បួនដង្ហែព្រះបរមសពនឹងកាត់តាមនោះ-នៅទីនេះគេដឹងថា សម្តេចឪឈឺខ្លាំង ហើយនិងចូលទិវង្គតឆាប់ៗហើយ ។ ថ្វីត្បិតតែដឹងថា នរណាក៏ស្លាប់ដែរក៏ដោយតែគេនៅតែព្រួយពីមរណភាពរបស់សម្តេច ហើយបារម្ភថា គ្រោះកាចនឹងមកដល់ថ្ងៃណាមួយទៀត ...ខ្ញុំបានឃើញមនុស្សយំដោយខ្សឹកខ្សួល ជាពិសេសស្ត្រីអាយុលើសពី៤០ឆ្នាំ ដែលជាមនុស្សធ្លាប់ទទួលនូវការខ្មៅខ្មៅនៃកម្ពុជា( ១៩៧៥-១៩៩៨) ។

ប្រទេសកម្ពុជាកំពុងតែទទួលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកំពុងតែត្រឡប់ទំព័រប្រវត្តិសាស្ត្រថ្មី-រូបភាពដ៏មានឥទ្ធិពលនៃយន្តហោះចិនហោះដង្ហែព្រះបរមសពអតីតព្រះមហាវីរក្សត្រ បានបង្ហាញយ៉ាងជាក់ច្បាស់ដល់អ្នកសង្កេតការណ៍អន្តរជាតិថា មានការគាំទ្រពីប្រទេសចិនដល់ព្រះរាជាណាចក្រកម្ពុជាដោយសារតែរឿងនេះកម្ពុជាបានលុបចោលវត្តមានរបស់ខ្លួនក្នុងកិច្ចប្រជុំកំពូលនៃប្រទេសឥណ្ឌូចិនទាំងបីដែលត្រូវធ្វើនៅក្រុងហូជីមិញនៅប៉ុន្មានថ្ងៃខាងមុខនេះ-គឺជាឱកាសល្អមួយសម្រាប់កម្ពុជា ដើម្បីចៀសវាងការវិវឌ្ឍន៍លឿនពេកនៅ"ត្រីកោណអភិវឌ្ឍន៍"ដែលកូននាគវៀតណាមចង់បានឬបង្ខំឱ្យធ្វើ ។ មរណភាពរបស់សម្តេចឪអនុញ្ញាតិឱ្យកម្ពុជាបង្ហាញឡើងច្បាស់មកវិញនូវអត្ថន័យដូចជា ឯករាជ្យភាព-បូរណភាពទឹកដី-អំណាចគ្រប់គ្រង និងបង្ហាញចំណងរបស់ខ្លួនដើម្បីឱ្យគេរាប់រកដូចជាប្រជាជាតិដទៃឱ្យមានសម្លេងមួយនៅក្នុងរង្វង់នៃសហប្រជាជាតិ ។ ព្រះរាជាណាចក្រកម្ពុជាថ្មីកំពុងបង្ហាញបំណងថា ចង់ឃើញអនាគតខ្លួនចេញរួចពីការចង់ត្របាក់ពីបងធំជិតខាងទាំងពីរ?

**ឌីខេ(DK):** ខ្ញុំមិនដឹងថា ជាការឧទ្ទិសដល់សពស្តេចដែលឱ្យតម្លៃថាជា"អទិទេព-ស្តេច" ឬយ៉ាងណាទេ ដោយសារតែតាមប្រវត្តិសាស្ត្រ"អទិទេព-ស្តេច"បានត្រូវបោសសំអាតកំទេចអស់រលីងដោយក្រុមបដិវត្តពុទ្ធសាសនិករបស់តាជៃនាសតវត្សរ៍ទី១៤។ ម្យ៉ាងទៀតពាក្យ "អទិទេព-ស្តេច"បានត្រូវបង្កើតឡើងដោយ ជច សឺដេស នៅសតវត្សទី២០ ដោយយោងទៅតាម "អទិទេព-ស្តេច"នៃប្រទេស អេជីប ដែលបារាំងឱ្យន័យថា ជាស្តេចមានអំណាចទេព្ដា ហើយនេះគ្មានអ្វីទាក់ទងទៅនឹងសក្រវាកនៃជ័យវរ្ម័នទី២ទេ ។

តែអ្វីដែលត្រឹមត្រូវនោះ គឺប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិបានវាយតម្លៃជាឯកឆន្ទថា "នរោត្តម សីហនុ បានជិតជាប់ទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសរបស់ព្រះអង្គ"ហើយប្រវត្តិសាស្ត្រនោះជាអ្វីទៅ?

អ្វីដែលច្បាស់លាស់នោះ គឺគេមិនអាចបំភ្លេចបានភ្លាមៗថា : ថ្ងៃស្អែកគេនឹងឃើញគ្រប់គ្នាខ្មែរនឹងបរទេសប្រើប្រាស់"គេរ្តិ៍អាកវនយោបាយ" របស់ឪ ដើម្បីគាំទ្រសកម្មភាពផ្ទាល់តែរៀងៗខ្លួន។ ប្រវត្តិសាស្ត្រត្រឡប់មកម្តងទៀត កើតជាបន្តទៅទៀត ប៉ុន្តែគ្មានន័យអ្វីទាល់តែសោះ។

**ណន ហ៊ី :** ខ្ញុំយល់ដូចប្រ្វេតឪដែរថា ដើមឈើមួយមិនអាចលាក់ព្រៃមួយបានទេ ខ្ញុំជឿថា បើគ្មាននរោត្តម សីហនុ ទេនោះទាំងស្រីទាំង ប្រុស យើងមិនអាចយកបានសញ្ញាប័ត្រខ្ពស់បានមួយជីវិត ដូច្នេះយើងចូលរួមមរណទុក្ខជាមួយព្រះញាតិ វង្ស...យ៉ាងស្ញប់ស្ញាត។

តទៅទំព័រទី ១៦

Mekong River
VIETNAMESE RESTAURANT
1120-1124S Front St.,
Philadelphia, PA 19147
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ
215-467-6100

GRAND OPENING
25-5-2012

មានម្ហូបវៀតណាមគ្រប់មុខ
ហ្វើ មី គុយទាវ នំបញ្ចុក បាញ់ហយ
បាយ ម្ហូបបួស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណៈគ្រួសារ
ទទួលពិធីជប់លៀងជាលក្ខណៈគ្រួសារ ឬជួបជុំមិត្តភ័ក្រ
BYOB






មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគមន៍យើង

# ពិធីគោរពវិញ្ញាណក្ខន្ធសម្តេច ព្រះនរោត្តម សីហនុ នៅឡូវែល






ក្រោមអធិបតីភាពនៃលោក ប៉ាទ្រីត ម័រហ្វី អភិបាលក្រុងឡូវែលចូលរួមជាគណអធិបតីដោយព្រះរាជបុត្រច្បងនៃអតីតព្រះមហាក្សត្រ គឺព្រះអង្គម្ចាស់នរោត្តម យុវនាថ ដោយថ្នាក់ដឹកនាំដូចជាលោក វ៉ាស្នា ទួន គណក្រុមប្រឹក្សាក្រុង លោក ថាច់ ប៊ុនរឿង ឧត្តមសេនីយ៍ ជុំ ឈាង លោក អ៊ុង ឫទ្ធី អតីតក្រុមប្រឹក្សាក្រុងលោក អ៊ូ សុវណ្ណ អគ្គកុងស៊ុលខ្មែរ ។ល។ ព្រមទាំងប្រជាពលរដ្ឋប្រមាណ ១០០នាក់ បានប្រារព្ធពិធីបង្ហូតទង់ជាតិចុះពាក់កណ្តាល កាលពីថ្ងៃសៅរ៍ ទី២០ ខែតុលា ឆ្នាំ២០១២ ជាសញ្ញាចូលរួមមរណទុក្ខជាមួយប្រជាពលរដ្ឋខ្មែរនៅកម្ពុជា ជាមួយព្រះញាតិវង្ស នាឱកាសចូលទិវង្គតរបស់អតីតព្រះមហាក្សត្រនរោត្តមសីហនុ ។

លោក វ៉ាស្នា ទួន បានបញ្ជាក់ថា "ពិធីនេះរៀបចំឡើងជាមួយសហគមន៍ខ្មែរដែលកាន់ទុក្ខការបាត់បង់អតីតព្រះមហាក្សត្រដែលបានធ្វើការលះបង់ដ៏ច្រើនដើម្បីសេចក្តីសុខនៃពលរដ្ឋខ្មែរ"...។ ឡូវែលជាទីក្រុងតូចមួយដែលមានសហគមន៍ខ្មែរច្រើន( ប្រមាណ៣ម៉ឺន) រស់នៅ ។ ជាក្រុងដែលមានលំដាប់ថ្នាក់លេខ២ នៃចំនួនពលរដ្ឋច្រើនបន្ទាប់ពីក្រុងឡុងប៊ិច ដែលផ្តល់ស្ថិតិ( មានមនុស្ស ៦ម៉ឺននាក់រស់នៅ) ។









# ជាប់ពន្ធនាគារ ៣ខែ តែត្រូវព្យួរ និងពិន័យប្រាក់ ចូលរដ្ឋ២លានរៀល ចំពោះការធ្វើឱ្យខូចរូបព្រះចន្ទដែលមានព្រះភក្ត្រសម្ដេចតា

**ដោយៈ ដើមអម្ពិល-ស៊ន សុភក្រ្ត**

**កណ្ដាលៈ** ក្រោយពីបើកសវនាការនាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២រួចមកនៅរសៀលថ្ងៃដដែលវេលាម៉ោង៤និង៣០នាទី ចៅក្រមសាលាដំបូងខេត្តកណ្ដាលលោក លឹម សុគន្ធា បានសម្រេចដាក់ពន្ធនាគារស្ត្រីជនជាតិចិនឈ្មោះ លីវ គុយស៊ាង អាយុ៥០ឆ្នាំ មាន





តួនាទីជាមេការផ្នែកដេរនៃរោងចក្រកាត់ដេរញូអាកឃីត ចំនួន៣ខែ តែត្រូវព្យួរ ហើយសម្រេចឱ្យបង់លុយចូលរដ្ឋ២លានរៀលពីបទធ្វើឱ្យខូចខាតដោយចេតនា យោងតាមមាត្រា៤១០នៃក្រមព្រហ្មទណ្ឌដែលស្ត្រីជនជាតិចិនរូបនេះ បានធ្វើឱ្យរូបព្រះចន្ទមានព្រះភក្ត្រសម្ដេចតានៅក្នុងនោះខូចខ្ទី ដែលជាកម្មសិទ្ធិរបស់ស្ត្រីឈ្មោះ ឆន សុភា អាយុ៤២ឆ្នាំ ជាកម្មការិនីកាត់ដេរ នៅរោងចក្រខាងលើ ។

ប្រភពព័ត៌មានពីមន្ត្រីអាវុធហត្ថ លើផ្ទៃប្រទេសបានឱ្យដឹងថា កាលពីវេលាម៉ោង៧និង៤នាទី ព្រឹកថ្ងៃទី២៣ ខែតុលា ស្ត្រីជនជាតិចិន លីវ គុយស៊ាង បានយកក្រដាសដែលមានរូបព្រះចន្ទពីឈ្មោះ ឆន សុភា ភេទស្រី អាយុ ៤២ឆ្នាំ ជាកម្មការិនីកាត់ដេរនៃរោងចក្រខាងលើមកកាន់ក្នុងដៃធ្វើឱ្យខូចខ្ទីជាហេតុនាំឱ្យកម្មករកម្មការិនីផ្ទុះការតវ៉ា ដោយពួកគេយល់ឃើញថា ជាការមើលងាយ និងប្រមាថទៅលើព្រះមហាវីរក្សត្រដែលពួកគេគិតថា រូបព្រះមហាវីរក្សត្រស្ថិតនៅក្នុងព្រះចន្ទនោះ ។

យោងតាមការសារភាពរបស់ស្ត្រីជនជាតិចិន ដែលនាំឱ្យរូបគេយករូបក្រដាសដែលមានរូបព្រះចន្ទនេះ មកកាន់ក្នុងដៃធ្វើឱ្យខូចខ្ទីនោះ ដោយសារតែពេលខ្លួនចូលទៅក្នុងអគារបេទីដែលខ្លួនមើលការខុសត្រូវ ស្រាប់តែឃើញក្រុមកម្មករនាំគ្នាមើលក្រដាសនោះ ហើយមិនធ្វើការក៏យកក្រដាសនោះមកកាន់មិនឱ្យមើលដោយមិនទាន់ដឹងថា ជារូបអ្វីនោះឡើយ ។

តាមរយៈការឱ្យស្ត្រីជនជាតិចិនរូបនេះ ធ្វើដំណើរពីរោងចក្រ រហូតដល់ទីបញ្ជាការអាវុធហត្ថដោយដោះស្បែកជើស្ត្រីជនជាតិចិនឯង និងលើកដៃសំពះសុំទោសព្រះមហាវីរក្សត្រដោយមានក្រុមកម្មករកម្មការិនីឃ្លាំមើលចំពោះការសុំទោសនេះ ។ ធ្វើការសុំទោសរួចមកទើបសមត្ថកិច្ចក៏បាននាំមកកាន់សាលាដំបូងខេត្តកណ្ដាលដើម្បីបើកសវនាការនិងកាត់ទោសទៅតាមផ្លូវច្បាប់ ៕




# នរោត្តមសីហនុ

**គីម សុស**

នេះជារឿងមួយជ្រុងតូចរបស់សម្ដេចព្រះបាទនរោត្តមសីហនុ តាមបទពិសោធន៍របស់ខ្ញុំ គឺតាមឮឃើញ និងដឹង គឺមិនមែនតាមឯកសារ ឬសៀវភៅណាមួយទេ ។

សម្ដេចជាព្រះបិតាឯករាជ្យនៃប្រទេសខ្មែរ ខ្ញុំជឿច្បាស់ ។ នៅមុនព្រះអង្គដាក់រាជ្យលើកដំបូងនៅឆ្នាំ១៩៥៥ខ្មែរយ៉ាងតិច៩០ភាគរយគោរពព្រះអង្គដូចព្រះ សូម្បីតែព្រះឆាយាល័ក្ខណ៍ធ្លាក់នៅលើដីក៏មិនហ៊ានដើរក្រឡងដែរ ។ នៅពេលនោះខ្ញុំតែងតែឮចាស់ៗមានប្រសាសន៍ថា ជួនកាលឃើញរូបព្រះអង្គនៅលើលោកខែ ។ តាំងពីពេលដាក់រាជ្យមកការគោរពរបស់ប្រជាពលរដ្ឋខ្មែរចំពោះព្រះអង្គធ្លាក់ចុះយ៉ាងច្រើន តែមិនចុះដល់ក្រោម៧០ភាគរយទេជាទូទៅនៅពេលណាក៏ដូចពេលណាដែរ ទោះជានៅពេលខ្មែរក្រហមក៏ដោយ ។ ចុះច្រើនបំផុតនៅក្នុងជួរបញ្ញវ័ន្ត ចំពោះក្នុងចំណោមប្រជាពលរដ្ឋធម្មតាមិនសូវចុះទេ ។



រឿងធំជាងគេដែលធ្វើឱ្យធ្លាក់នោះ មកពីព្រះអង្គលូកដៃចូលក្នុងនយោបាយមានន័យថា ចូលជាមួយនឹងមនុស្សធម្មតា ។ គេទុកព្រះជាព្រះ មិនមែនមនុស្សធម្មតាទេ ។

មូលហេតុដែលធ្វើឱ្យព្រះអង្គដាក់រាជ្យ ហើយមកធ្វើនយោបាយនោះ មកពីព្រះអង្គខ្លាចបាត់អំណាច ។ ត្រង់នេះព្រះអង្គយល់តាមទីប្រឹក្សារបស់ព្រះអង្គដែលយោងតាមលទ្ធិប្រជាធិបតេយ្យ គឺអំណាចនៅក្នុងដៃរាស្ត្រ ។ តាមពិតមិនដូច្នោះទាំងអស់ទេ ។ ឥឡូវនេះប្រទេសខ្មែរកាន់លទ្ធិប្រជាធិបតេយ្យតែអំណាចមិនក្នុងដៃរាស្ត្រទេតាមពិត ។

ព្រះអង្គជឿតាមទីប្រឹក្សារបស់ព្រះអង្គតាមខ្ញុំឮ ។ តែទោះជាយ៉ាងនេះក៏ដោយការទទួលខុសត្រូវនៅលើព្រះអង្គទាំងស្រុងមិនអាចប្រកែកបាន ។ នេះជាកំហុសស្លាប់រស់របស់ព្រះអង្គ ។

ចំពោះខ្ញុំ បើព្រះអង្គមិនដាក់រាជ្យពេលនោះខ្មែរក្រហមមិនអាចកើតមានបានទេ ហើយសភាពការណ៍ប្រទេសខ្មែរក៏មិនធ្លាក់ដល់សភាពការណ៍សព្វថ្ងៃនេះដែរ មានន័យថា សម្បូរណ៍សប្បាយជាង ។

កាលមុនដាក់រាជ្យប្រជាពលរដ្ឋមិនតិចជាង៩០ភាគរយដើរតាមមានចិត្តស្រឡាញ់គោរពចេញពីដួងចិត្តខ្លួនឯង ព្រះអង្គដឹងទុក្ខធុរៈរបស់ប្រជាពលរដ្ឋយកចិត្តទុកដាក់បណ្ដុះបណ្ដាលយុវជន បង្កើតសាលារៀនគ្រប់ជាន់ថ្នាក់បញ្ជូនសិស្សទៅរៀននៅបរទេស ព្រះអង្គចេះសប្បាយព្រះអង្គមានទស្សនៈមួយ គឺខ្លួនឯងសប្បាយដោយឃើញគេសប្បាយព្រះអង្គធ្វើឱ្យរាស្ត្រសប្បាយមានបានរុងរឿងស្ថាប័នរាជានិយមរឹងមាំប្រៀបបាននឹងស្ថាប័នព្រះពុទ្ធសាសនា។ ដូច្នេះឃើញថា ប្រទេសខ្មែររឹងមាំសំបើមមិនអាចប្រទេសណាមកជ្រៀតជ្រែកបានទេ ។



ព្រះអង្គទាមទារបានឯករាជ្យដោយសារប្រទេសខ្មែររឹងមាំនោះឯង ៕

# ខ្មែររស់នៅ ស.រ.អា.ធ្វើបាតុកម្មគាំទ្រថ្ងៃទី ២៣ តុលា ១៩៩១ នៅ អ.ស.ប

**ដោយ: ម៉ម យីន**

**ពីញូវយ៉ក :** យោងតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ១៩៩១ ស្តីពីការបញ្ចប់សង្គ្រាមខ្មែរក្នុងគោលបំណងដូចតទៅ :

**១-**ត្រូវបញ្ចប់សង្គ្រាមសម្លាប់ជនជាតិខ្មែរ ដែលបានកើតយ៉ាងយូរអស់រយ:ពេលជាង២ទសវត្សមកហើយ ។

**២-**អោយមានផ្សះផ្សាជាតិបង្រួបបង្រួមជាតិអោយមានឯកភាពជាតិជាជាតិខ្មែរតែមួយពិតប្រាកដ ។

**៣-**អោយមានសុខសន្តិភាព ឯករាជ្យភាព បូរណភាព និងអធិបតេយ្យភាពទឹកដី និងសិទ្ធិសេរីភាពពេញបរិបូរពិតប្រាកដទោតាមគោលការណ៍លទ្ធិប្រជាធិតេយ្យ សេរីពហុបក្សពិតប្រាកដ ។






**៤-**ដើម្បីស្ថាបនាកសាងប្រទេសអោយបានរីកចំរើនលូតលាស់នូវហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យអោយប្រជាពលរដ្ឋខ្មែរទាំងអស់គ្នាត្រូវតែបានរួចចេញផុតពីភាពក្រីក្រតោកយ៉ាកលំបាករហេមរហាម អត់ឃ្លាន និងអោយរួចពីអំណាចជិះជាន់សង្កត់សង្កិនគ្រប់បែបយ៉ាង ។

**៥-**អោយមានការបោះឆ្នោតជាសកលជ្រើសរើ មេដឹកនាំថ្មី ដែលប្រកបដោយ សេរីសុចរិត យុត្តិធមិ ល្អត្រឹមត្រូវ និងមានតម្លាភាពពិប្រាកដតាមច្បាប់និតិរដ្ឋសម្រាប់គណបក្សនយោបាយទាំងអស់ ទាំងកំពុងកាន់អំណាច ទាំងមិនទាន់បានកាន់អំណាចអោយបានពេញលក្ខណ:សម្បត្តិនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដ ។

ដោយសារតែមានអត្ថន័យ និងខ្លឹមសារដ៏មានអាទិភាពសំខាន់បំផុត នៃសន្ធិសញ្ញាអន្តរជាតិក្រុងប៉ារីស២៣តុលា១៩៩១នេះហើយ ដែលបានជួយជ្រោមជ្រែងឧបត្ថមគ្រប់បែបយ៉ាងជួយសង្គ្រោះដល់កម្ពុជា និងប្រជាពលរដ្ឋខ្មែរ រហូតមកដល់សព្វថ្ងៃនេះជាពិតប្រាកដណាស់ ។

អាស្រ័យហេតុនេះ យើងខ្ញុំជាជនជាតិខ្មែររស់នៅឯនាយសមុទ្រ បានដឹងនិងយល់ជាក់ច្បាស់ថា ថ្ងៃ ទី២៣ តុលា១៩៩១ គឺពិតជាថ្ងៃជួយសង្គ្រោះជីវិតកម្ពុជា និងប្រជាជាតិខ្មែរ ទើបយើងខ្ញុំចេញមកពីរដ្ឋនានា មួយចំនួនស្ថិតនៅជិតទីស្នាក់ការអង្គការសហប្រជាជាតិក្រុងញូវយ៉កតាំងពីព្រលឹមម៉ោង៨ព្រឹកថ្ងៃទី១៩ ខែតុលាឆ្នាំ២០១២ ក្រោមការដឹកនាំ និងចាត់ចែងរៀបចំពីលោក ម៉ៃឃល ដួង និងលោក ចន្ទលី គុជ ព្រមទាំងប្រជាពលរដ្ឋខ្មែរទាំងប្រុសទាំងស្រីទាំងក្មេងចាស់ប្រមាណជាជិតមួយរយនាក់ ដូចជាមកពីរដ្ឋក្លូរ៉ូ លីណា ខាងជើងរដ្ឋម៉ារីឡិន រដ្ឋផែនស៊ុលវៃនីញ៉ា រដ្ឋញូវហ្សិក ស៊ី រដ្ឋញូវយ៉ក រដ្ឋរ៉ូតអៃឡិនជាដើម ។

បងប្អូនរួមជាតិខ្មែរដៃកាន់បដាផ្ទាំងពាក្យស្លោកដ៏មានអត្ថន័យសំខាន់ៗមានជាអាទិថា "មានតែថ្ងៃទី២៣ តុលា១៩៩១ ទេ ដែលជួយសង្គ្រោះកម្ពុជាអោយបានសុខសន្តិភាព និងរីកចំរើនពិតប្រាកដមិនមែនថ្ងៃ៧មករា ១៩៧៩ឡើយ" "សូមអ.ស.ប.ដាក់បញ្ញត្តិជាកំហិតដល់រដ្ឋាភិបាលខ្មែរ អោយគោរពតាមសន្ធិសញ្ញា២៣តុលា១៩៩១" "ជយោថ្ងៃទី២៣ តុលា ១៩៩១" "ហ៊ុនសែន ត្រូវតែបញ្ឈប់អំពើផ្តាច់ការឃោរឃៅទៅ" "កម្ពុជាត្រូវតែមានឯករាជ្យនិងសិទ្ធិសេរីភាពពិតប្រាកដ" "រលំរលាយទៅ ហ៊ុន សែន ដើម្បីអោយប្រជាជាតិខ្មែរបានរស់នៅជាងរៀងរហូត" ។ល។ និង ។ល។ នៅមានពាក្យស្លោកជាច្រើនទៀត ។

នៅម៉ោង៩ និង៣០ នាទីព្រឹកលោក ម៉ៃឃលដួង និងលោក ចន្ទលី គុជ ជាតំណាងអោយប្រជាពលរដ្ឋខ្មែរទាំងអស់ បានចូលទៅកាន់ការិយាល័យអង្គការសហប្រជាជាតិ ដើម្បីនាំយកញត្តិស្នើសុំ និងអំពាវនាវដល់លោកអគ្គលេខាធិការអ.ស.ប.បានគឺមូនសូមជួយធ្វើអន្តរាគមន៍យ៉ាងខ្លាំងក្លាបំផុតទៅដល់សហប្រធានសន្និសិទ្ធក្រុងប៉ារីសទាំងពីរមកពីប្រទេសបារាំង និងឥណ្ឌូនេស៊ីព្រមទាំងប្រទេសទាំង១៨ ដែលជាហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិ២៣ តុលា ១៩៩១ នោះ ត្រូវតែលើកឡើងនូវកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនេះមកធ្វើការយ៉ាងហ្មឹងម៉ាត់ទៅដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន អោយត្រូវតែគោរពធ្វើតាមជាដាច់ខាតនូវអត្ថន័យ និងខ្លឹមសារសំខាន់ណាស់អោយបានមុនពេលបោះឆ្នោតសកលថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ។ ជាពិសេសដើម្បីអោយមានគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប. សុចរិត សេរី យុត្តិធមិ ល្អត្រឹមត្រូវមានឯករាជ្យ អព្យាក្រិត និងតម្លាភាពពិតប្រាកដសម្រាប់ផ្តល់គតិយុត្តិធមិអោយដល់គណបក្សនយោបាយទាំងអស់ ក្នុងការជ្រើសរើសសមាជិកសភាតំណាងរាស្ត្រ ដើម្បីអោយក្លាយទៅជានាយករដ្ឋមន្ត្រីថ្មីដឹកនាំកម្ពុជា និងប្រជាជាតិខ្មែរនៅក្នុងអណត្តិទី៥ខាងមុខនេះ សមស្របទៅតាមឆន្ទះប្រជាពលរដ្ឋខ្មែរទាំងអស់គ្នាដែលត្រូវការចង់បានជាចាំបាច់បំផុត តទៅ ។

ក្រោយពីបានដាក់ញត្តិស្នើសុំរួចហើយ ក្រុមបាតុករទាំងអស់ថ្លែងសេចក្តីសំដែងនូវមតិយល់ឃើញយ៉ាងជាក់ច្បាស់ព្រមទាំងស្រែកអំពាវនាវស្នើសុំយ៉ាងកងរំពងនូវពាក្យស្លោកសំខាន់ៗដោយព្រមៗគ្នាដែលតំណាងនៃរដ្ឋនិមួយៗបានសំដែងឡើង ដូចជាលោក ម៉ៃឃល ដួង លោក ចន្ទលី គុជ លោក ម៉ម យីន លោក ហេង វីរ: លោក អ៊ូ គីមហួត លោក ចាន់ស៊ាង លោកបណ្ឌិត គីមស៊ុយ ព្រមទាំងលោកស្រីអស់លោកមួយចំនួនទៀត សូមអភ័យទោសដែលមិនបានចាំឈ្មោះអស់ ។

ការសំដែង និងសុច្ឆន្ទះ រហូតដល់ម៉ោង១កន្លះរសៀល ចាប់តាំងពីពេលព្រឹកព្រលឹមយើងខ្ញុំពុំបានឃើញពន្លឺព្រះអាទិត្យរះសោះឡើយ ព្រះភិរុណបានបង្អុរចុះមកជាប់ជានិច្ចលាយទៅដោយខ្យល់ត្រជាត់បោះបោកមកម្តងតិចម្តងខ្លាំងធ្វើអោយបាតុករទាំងអស់គ្នាឈរនៅក្រោមតំណក់ទឹកភ្លៀងជារហូតពេញមួយថ្ងៃនេះម្តង ។

ទោះជាយ៉ាងនេះក៏ដោយយើងខ្ញុំជាតំណាងអោយជនជាតិខ្មែររស់នៅឯនាយសមុទ្រទាំង អស់ សូមសំដែងការឈឺចាប់ យ៉ាងខ្លាំងចំពោះប្រមុខរដ្ឋាភិបាលខ្មែរ ហ៊ុន សែន ដែល បានទាត់ចោល និងលុបចោលនូវសិទ្ធិអំណាចឥទ្ធិពលរបស់សន្ធិសញ្ញាអន្តរជាតិ២៣ តុលា ១៩៩១ ស្តីពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសសម្រាប់អោយកម្ពុជា និងជនជាតិខ្មែរគ្រប់និន្នាការនយោបាយអោយបានផ្សះផ្សាគ្នាបង្រួបបង្រួមគ្នាមានសាមគ្គីភាព និងឯកភាពជាជាតិខ្មែរតែមួយ ជួយស្ថាបនាកសាងប្រទេស និងហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ អោយរីកចំរើនលូតលាស់សារជាថ្មីឡើងវិញ ដោយមិនត្រូវអោយលោក ហ៊ុន សែន ប្រើអំណាចផ្តាច់ការប្រមូលអំណាចទាំងអស់អោយមកនៅក្នុងកណ្តាប់ដៃតែម្នាក់ឯងដូច្នេះឡើយ ៕

**រាយការណ៍ដោយ លោក ម៉ម យីន ពីញូយ៉ក**
**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១២**

**ត្រូវការជ្រើសរើសខ្មែរចូលធ្វើប៉ូលិសអូហ្វីសឺនៅហ្វីឡាដែលហ្វៀ**

***Become a Philadelphia Police Officer***

**215-683-COPS**

**www.phillypolice.com**

**Recruitment drive between September 17th, 2012 and November 9th, 2012**

*Starting salary $42,474 during training and $45,420 after graduation, with yearly increases
*Increased earning potential for current certified Law Enforcement Officers
*Excellent benefits package
*Exceptional promotional opportunity
*Tuition Reimbursement

**REQUIREMENTS:** Applicants must be 21 years of age with at least 3 years driving experience and meet **1** or more of the criteria below:

**1)** Completed at least 60 college credits from an *accredited* college, university or institution
**2)** Served at least 2 years, *active duty*, in any branch of the military with an honorable discharge.
**3)** Served at least 1 year of *full time* employment as a state certified law enforcement officer, anywhere in any state of the US.
**4)** Have successfully completed the Philadelphia Police Explorers Cadet program.

***For more information and to apply, go to *www.phila.gov/personnel***
**Must apply online by November 9th, 2012. Necessary documents must be uploaded electronically at the time of application or hand delivered on December 8th, 2012 at the Municipal Services Building, 1401 JFK Blvd Philadelphia, PA 19106**

**តមកពីទំព័រទី ១** សម្ភាសន៍ជាមួយ ជូលីយូ យែលជ្រេល...

នៅថ្ងៃច័ន្ទកន្លងទៅថ្មីៗនេះ ព្រះអង្គបានសោយទិវង្គតដែលធ្វើឱ្យសាធារណៈជនមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការជជែកវែកញែកទៅលើមរតកនៃស្នាមព្រះហស្ត ព្រមទាំងការចូលរួមជាមួយនឹងក្រុមខ្មែរក្រហមបន្ទាប់ពីមានរដ្ឋប្រហារដោយកំលាំងប្រដាប់អាវុធទម្លាក់ព្រះអង្គពីតំណែងក្នុងឆ្នាំ១៩៧០ ព្រះអង្គបានគាំទ្រ ប៉ុល ពត នៅឆ្នាំ១៩៧៦ ព្រះអង្គបានលាលែងពីប៉ុលពត ហើយក៏ជាការចាប់ផ្តើមការត្រួតត្រាទឹកដីនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។

ខាងក្រោមនេះជាកិច្ចសម្ភាសន៍ជាមួយ Julio Jelders ជាអ្នកចងក្រងជីវប្រវត្តិរបស់ព្រះមហាក្សត្រ និងជាអតីតជំនួយការផ្ទាល់នៃព្រះមហាក្សត្រ នរោត្តម សីហនុ ដែលបានចូលរួមផ្តល់បទពិសោធន៍ផ្ទាល់ខ្លួនអំពីអតីតព្រះមហាក្សត្រដ៏មានប្រជាប្រិយភាព ។ Julio Jelders សូមស្វាគមន៍ !

**Julio Jelders: សូមអរគុណ !**

**សំណួរ:** កាលពីពេលថ្មីៗនេះអ្នកបានជួបជាមួយព្រះមហាក្សត្រនរោត្តម សីហនុ ជាញឹកញាប់កាលព្រះអង្គនៅមានព្រះជន្មខ្ញុំចង់ដឹងថា តើព្រះអង្គមានគំនិតដូចម្តេចអំពីដំណើរការនូវកម្ពុជា និងផលប៉ះពាល់មួយចំនួនទៅលើការខ្វះខាតផ្នែកថវិការជាតិ?

**ចម្លើយ:** ជាបឋមព្រះមហាក្សត្រយល់ថា ការកាត់ក្តីខ្មែរក្រហមគួរប្រព្រឹត្តទៅដោយឯករាជ្យ និងមានការទទួលស្គាល់យ៉ាងពេញលេញពីសហគមន៍ជាតិក៏ដូចជាអន្តរជាតិ ប៉ុន្តែដោយមានការព្រមព្រៀងរវាងរដ្ឋាភិបាលខ្មែរ និងអង្គការសហប្រជាជាតិឱ្យមានតុលាការកូនកាត់ដែលបានដំណើរការកាត់ក្តីនៅកម្ពុជាកន្លងមកព្រះមហាក្សត្រក៏បានឯកភាពទៅតាមគំនិតរបស់ថ្នាក់ដឹកនាំព្រមទាំងសាធារណៈជនទូទៅផងដែរ ប៉ុន្តែខ្ញុំគិតថា ព្រះអង្គបានឯកភាពជាមួយតុលាការកូនកាត់ទាំងមិនរីករាយផ្ទុយពីហឫទ័យរបស់ព្រះមហាក្សត្រ ហេតុនេះព្រះអង្គបានសំរេចចិត្តថា លោកនឹងមិនជួបផ្ទាល់ជាមួយនឹងប្រជាជនអាមេរិកពាក់ពន្ធ័នឹងបញ្ហាកាត់ក្តី ទោះបីមានសំណូមពរចូលគាល់ព្រះអង្គក៏ដោយ ។

ព្រះអង្គតែងមានព្រះបន្ទូលជាញឹកញាប់ថា ថវិការគួរត្រូវបានចំណាយទៅលើប្រជាជនដែលត្រូវការថវិការដើម្បីសង្គ្រោះអាយុជីវិត និងប្រជាជនដែលកំពុងជួបប្រទះគ្រោះទុរភិក្សដោយខ្វះអាហារជាដើម ។

**សំណួរ:** តើព្រះអង្គបានគិតទុកនូវការតបស្នងទៅលើការបាត់បង់អាយុជីវិតរបស់ប្រជាជនរាប់លាននាក់ ដោយការសម្លាប់រង្គាលក្នុងរបបខ្មែរក្រហមថា តើប្រជាជនទាំងនោះសមនឹងទទួលបានយុត្តិធម៌ដែរឬទេ?

**ចម្លើយ:** ខ្ញុំគិតថា ព្រះអង្គចង់ឱ្យប្រជាជនដែលបានបាត់បង់ជីវិតទាំងនោះទទួលបាននូវយុត្តិធម៌យ៉ាងពិតប្រាកដ ទោះបីព្រះអង្គមិនមានវត្តមានក្នុងសវនការកាត់ក្តីមេដឹកនាំខ្មែរក្រហមក៏ដោយ ។ ការកាត់ទោសមេដឹកនាំប្រល័យពូជសាសន៍ខ្មែរក្រហមដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជាស្រដៀងគ្នាទៅនឹងករណីនៅប្រទេសយូហ្គោស្លាវី Yugoslavia ដែរ ។

**សំណួរ:** ខ្ញុំបានជួបព្រះអង្គជាច្រើនឆ្នាំកន្លងផុតទៅហើយបានកត់សម្គាល់ថា ព្រះអង្គមានអត្តចរិករស់រវើក និងប្រែប្រួល តើការវាយតម្លៃនេះសមហេតុផលឬទេ?

**ចម្លើយ:** ខ្ញុំមិនគិតដូចច្នេះឡើយ ខ្ញុំគិតថា ព្រះអង្គជាស្តេចដែលមិនអាចធ្វើការសន្និដ្ឋានបានឡើយ ទោះបីជារូបខ្ញុំធ្លាប់ជាជំនួយការផ្ទាល់របស់ព្រះអង្គជាច្រើនឆ្នាំក៏ដោយជារឿយៗខ្ញុំ មិនអាចទស្សន៍ទាយបានថា តើថ្ងៃស្អែកនឹងមានអ្វីកើតឡើង ។ ព្រះអង្គបានបំពេញព្រះរាជបូជនីយកិច្ចដើម្បីនាំមកនូវភាពជោគជ័យជូនប្រទេសកម្ពុជា ប៉ុន្តែព្រះអង្គមិនបានលះបង់ដើម្បីសំរេចជោគជ័យនូវមហិច្ឆិតាផ្ទាល់របស់សីហនុនោះឡើយ ។

ព្រះមហាក្សត្រនរោត្តមសីហនុបំពេញកិច្ចការដើម្បីប្រទេសកម្ពុជា ។

**សំណួរ:** ក្នុងអំឡុងឆ្នាំ ១៩៥០ និង១៩៦០ ព្រះបាទនរោត្តម សីហនុ បានធ្វើការតវ៉ាប្រឆាំងនិន្នាការត្រួតត្រាទឹកដីពីប្រទេសអាមេរិកប្រទេសវៀតណាមប្រទេសចិន និងប្រទេសរុស្ស៊ី បន្ទាប់មកព្រះអង្គទទួលបានជោគជ័យក្នុងយុទ្ធនាការនេះ តើព្រះអង្គបានគ្រប់គ្រងនូវស្ថានភាពបែបណាក្នុងការទទួលបានជោគជ័យក្នុងរយៈពេលខ្លី?

**ចម្លើយ:** មានបញ្ហាពីរដែលបានបញ្ចៀសឱ្យប្រទេសកម្ពុជាឃ្លាតចាកពីសង្គ្រាមរបស់ប្រទេសវៀតណាម

ទីមួយគឺការបង្រួបបង្រួមជាតិ និងទីពីរ គឺអព្យាក្រឹត្យភាព ។ ព្រះអង្គបានជំរុញនូវចលនាបង្រួបបង្រួមជាតិឱ្យផុសឡើងជាមួយនឹងមនសិការស្នេហាជាតិជាក់ស្តែង ព្រះអង្គតែងតែរៀបរាប់អំពីលទ្ធផលនៃព្រះរាជដំណើរយាងទៅក្រៅប្រទេសជូនដល់ជនរួមជាតិរបស់ព្រះអង្គធ្វើឱ្យពួកគេបានយល់នូវតួនាទីរបស់ខ្លួនក្នុងការរួមចំណែកកសាងប្រទេស ។ ព្រះអង្គបានប្រាប់អំពីទំនាក់ទំនងកិច្ចការបរទេស **តទៅទំព័រទី២០**

# ព្រះរាជជីវប្រវត្តិ



សម្តេចនរោត្តម សីហនុ ប្រសូតនៅថ្ងៃអង្គារ៍ ទី៣១ ខែតុលា ឆ្នាំ១៩២២ នាទីក្រុងភ្នំពេញ ព្រះអង្គជាបុត្រព្រះបាទនរោត្តម សុរាម្រិត (១៩៥៥-១៩៦០) ជាចៅរបស់ព្រះអង្គម្ចាស់ សុទ្ធារតន៍ ដែលជាបុត្រព្រះបាទសម្តេចនរោត្តម(១៨៥៩-១៩០៤) ។ ព្រះមាតារបស់ទ្រង់គឺសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរត្ន សេរីវត្តិនាដែលជាព្រះរាជបុត្រនៃព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស(១៩២៧-១៩៤១)យាយតួតព្រះអង្គគឺអ្នកម្នាងឃុនប៉ាន់ ជាអ្នកអប់រំលើព្រះអង្គកាលនៅរាជកុមារ ។ លុះលោកយាយអនិជកម្មទៅភារកិច្ចនេះត្រូវធ្លាក់ទៅលើព្រះអយ្យការខាងបិតាវិញ ។ ដូចនេះព្រះអង្គម្ចាស់នរោត្តមសុទ្ធារតន៍ ដែលជាអ្នកអក្សរសាស្ត្រជាតិនិងជាកវីផងនោះ គឺជាអ្នកបីបាច់គ្រប់គ្រងកិច្ចការ លើព្រះរាជកុមារ សីហនុ នៅឆ្នាំ១៩៣០-១៩៤០ ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា Francois Baudoin និងវិទ្យាល័យ ស៊ីសុវត្ថិ ។ បន្ទាប់មកព្រះអង្គបានបន្តការសិក្សានៅវិទ្យាល័យបារាំងសាសលូឡូបា (Lyceé Chasseloup Laubat) នៅព្រៃនគរ ។ ឆ្នាំ១៩៤៦និង១៩៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់នៅសាលាអនុវត្តន៍ទ័ពសេះ និងទ័ពរថពាសដែក នៅ Saumur ប្រទេសបារាំង ។

**ការគ្រងរាជលើកទី១**

ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសតាំង និងថ្វាយរាជឋានៈព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៨ខែតុលា ឆ្នាំ ១៩៤១ ។ ប៉ុន្តែព្រះអង្គបានដាក់រាជ្យថ្វាយព្រះបិតាវិញនៅថ្ងៃ០២ខែមិនា ឆ្នាំ១៩៥៥ ពោលគឺបន្ទាប់ពីទទួលបានរាជ្យពីបារាំង ។

**ការគ្រងរាជ្យលើកទី២**

បន្ទាប់ពីបានដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិចព្រមទាំងបានដឹកនាំចលនាត្រីភាគី (ហ្វ៊ុនស៊ិនប៉ិច រ.ជ .រ.បខ កម្ពុជាប្រជាធិបតេយ្យ) ដើម្បីប្រឆាំង និងរដ្ឋការលោក ហ៊ុន សែន រួចមកទើបកិច្ចចរចាសន្តិភាពនាទីក្រុងប៉ារីសថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១ បានចាប់បដិសន្ធិឡើង ។ បន្ទាប់ពីនោះព្រះអង្គបានយាងនិវត្តន៍ចូលមាតុភូមិកំណើតជាថ្មី ហើយបានគ្រងរាជសម្បត្តិជាលើកទី២ នៅថ្ងៃទី២៤ខែកញ្ញា ឆ្នាំ១៩៩៣ ប៉ុន្តែទីបំផុតទ្រង់បានដាក់រាជ្យវិញ នៅថ្ងៃទី៧ខែតុលាឆ្នាំ២០០៤ និងទទួលបានព្រះនាមជា"ព្រះមហាវីរក្សត្រ" ៕

**តមកពីទំព័រទី ១** ការចូលទិវង្គត និងព្រះរាជប្រវត្តិរបស់សម្តេច...

ប្រជាពលរដ្ឋខ្មែរ និងពីសំណាក់ក្រុមអ្នកនយោបាយខ្មែរ ។ ជាពិសេសប្រទេសមហាអំណាចធំៗមួយចំនួនក៏បានចូលរួមកាន់ទុក្ខចំពោះការបាត់បង់គ្រាប់គុជនៅអាស៊ីមួយនេះផង





ដែរ ។ ទោះបីជាមួយរយៈចុងក្រោយនេះសម្តេច សីហនុ ហាក់ពុំសូវបានគង់ប្រថាប់ក្នុងប្រទេសរបស់ខ្លួនក្តីតែប្រជាពលរដ្ឋខ្មែរមួយចំនួនធំ ហាក់សំដែងនូវចិត្តភក្តី ចំពោះព្រះអង្គជានិច្ច ហើយការគោរពដ៏ជ្រាលជ្រៅនេះត្រូវបានកើតឡើងលើប្រជាពលរដ្ឋខ្មែរដែលមានវ័យចំណាស់ៗនៅតាមជនបទស្រុកស្រែចំការ ។

ទោះបីជាមានព្រះជន្មយ៉ាងច្រើនរហូតដល់៩០ព្រះវស្សាហើយក្តីតែការចូលទិវង្គតរបស់ម្តេចនរោត្តម សីហនុ ហាក់បីដូចជាឆាប់រហ័សពេក ព្រោះរាល់អាថ៌កំបាំងនៃវាសនារបស់ប្រទេសជាតិ គឺស្ថិតនៅក្នុងព្រះអង្គទាំងអស់ ។ ទាំងអស់នេះហើយដែលជាក្តីបារម្ភរបស់ប្រជារាស្ត្រខ្មែរដែលពួកគាត់និយាយ និងដាក់សំនួរតៗគ្នាថា "តើវាសនាប្រទេសជាតិនឹងក្លាយទៅជាយ៉ាងណានៅពេលសម្តេចឪចូលទិវង្គតនោះ? " ។

ថ្វីបើស្តេច សីហនុ ត្រូវបានប្រជារាស្ត្រខ្មែរភាគច្រើនហៅថា "សម្តេចឪ" ព្រោះដោយសារតែព្រះអង្គមានគុណបំណាច់យ៉ាងខ្លាំងចំពោះប្រទេសជាតិ ក្នុងការទាមទារនូវឯករាជ្យភាពពីអាណានិគមនិយមបារាំងនាថ្ងៃទី៨ ខែវិច្ឆិកាឆ្នាំ១៩៥៣ក្តី តែព្រះអង្គក៏ត្រូវបានទទួលនូវការស្តីបន្ទោស និងមានការប្រឆាំងយ៉ាងពេញទំហឹងពីសំណាក់អ្នកនយោបាយខ្មែរ និងប្រជាពលរដ្ឋខ្មែរមួយចំនួន ។

ការបណ្តែតបណ្តោយឱ្យពលរដ្ឋយួនហូរចូលស្រុកខ្មែរដោយខុសច្បាប់នាទសវត្សរ៍ឆ្នាំ១៩៦០-១៩៧០ និងការផ្តល់នូវស្បៀងឱ្យក្រុមវៀតមិញ ក្នុងខណៈដែលស្រុកទេសកំពុងតែអត់ឃ្លាន គឺជាបរិបទដែលឱ្យប្រជាពលរដ្ឋខ្មែរងើបឈរប្រឆាំងនឹងព្រះអង្គ ។ ក្រៅពីនោះការកាត់ទោសប្រហារជីវិតលើក្រុមចលនាខ្មែរសេរីដែលប្រឆាំងនឹងព្រះអង្គ ដោយមានលោក សឺង ង៉ុកថាន់ ជាអ្នកដឹកនាំក៏បានជំរុញឱ្យប្រជាពលរដ្ឋខ្មែរមួយចំនួនកាន់តែស្គាល់អំពីអត្តចរិតរបស់ព្រះអង្គកាន់តែខ្លាំង ហើយរលកនៃការប្រឆាំងនឹងទ្រង់ កាន់តែរីកសាយភាយភ្លាមដែរ ។

អ្វីៗដែលគេនៅចាំគឺស្តេច សីហនុ បានគៀងគរឱ្យរាស្ត្ររត់ចូលព្រៃមាគី (Marquis) ដើម្បីកាន់អាវុធតស៊ូប្រឆាំងនឹងរបបសាធារណៈរដ្ឋបន្ទាប់ពីលោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គកាលពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ នោះ ។

គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C ) Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

# គណកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងក្នុងពិភពលោក

បារីសថ្ងៃទី ២០ តុលា ឆ្នាំ២០១២

## ផលវិបាកនៃសន្ធិសញ្ញាដែលបានចុះជាមួយប្រទេសវៀតណាម

ក្នុងឆ្នាំ១៩៧៩-១៩៨២-១៩៨៣-១៩៨៥-២០០៥

### ក/ សន្ធិសញ្ញាចុះថ្ងៃទី ១៨ កុម្ភៈ ១៩៧៩

សន្ធិសញ្ញានេះជាសន្ធិសញ្ញាគ្រឹះឈ្មោះថា "សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ"ជាមូលដ្ឋានសម្រាប់ធ្វើកិច្ចព្រមព្រៀងនានាបន្តទៀត ។ សន្ធិសញ្ញានេះបានបញ្ជាក់យ៉ាងច្បាស់ថា"មានសុពលភាព២៥ឆ្នាំ ហើយនឹងបន្តទៅទៀតជាតុណ្ហីភាពក្នុងរយៈពេល១០ឆ្នាំម្តង បើភាគីម្ខាងនៃភាគីទាំងពីរមិនបានឱ្យដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត ក្នុងរយៈពេល១ឆ្នាំ មុនការផុតកំណត់នៃសុពលភាព នូវបំណងរបស់ខ្លួនក្នុងការលុបចោលសន្ធិសញ្ញានេះទេ"។

សន្ធិសញ្ញានេះបានចងប្រទេសយើងភ្ជាប់ជានិច្ចជាមួយប្រទេសវៀតណាម ពុំមែនក្នុងភាពស្មើគ្នានោះទេ តែក្នុងឋានៈជាអ្នកទន់ខ្សោយ ទោះបីសន្ធិសញ្ញានេះបានប្រកាសក្លែងៗពី"យុទ្ធសាមគ្គី និងសមិទ្ធិផលបដិវត្តន៍ដ៏មហិមាដែលត្រូវឆ្លងកាត់ការតស៊ូជិត៣០ឆ្នាំ " យ៉ាងណាក៏ដោយ ។

### ខ/កិច្ចព្រមព្រៀងចុះថ្ងៃទី៥កក្កដា ១៩៨២

កិច្ចព្រមព្រៀងដែលបន្តមកទៀត បានយោងទៅលើសន្ធិសញ្ញាថ្ងៃទី ១៨ កុម្ភៈ ១៩៧៩ ខាងលើសនេះ ។ កិច្ចព្រមព្រៀងនេះ បានបង្កើតតំបន់មួយហៅថា"តំបន់ទឹកប្រវត្តិសាស្ត្រ"ទំហំប្រមាណ១០០០០គម² ដែលគេដាក់ក្នុងការគ្រប់គ្រងរួម និងទទួលស្គាល់ការកាត់យកដោយសាធារណរដ្ឋសង្គមនិយមវៀតណាមនូវកោះខ្មែរជាច្រើន និងមួយភាគបី(៣០០០០គម²)នៃផ្ទៃសមុទ្ររបស់ប្រទេសកម្ពុជា ។

ឯចំណែកសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ បែរជាអួតអាង សរសើរពីអធិបតេយ្យភាពដ៏ពេញលេញរបស់ខ្លួននៅលើតំបន់នេះ ថែមទាំងបានថ្លែងពីការទទួលស្គាល់ដោយភាគីវៀតណាមនូវអធិបតេយ្យភាពរបស់ខ្មែរទៅលើកោះពូឡូវៃទៀតផង ថ្លែងនេះហាក់បីដូចជាកោះនេះ ជាកោះរបស់យួន...

យើងត្រូវបញ្ជាក់ថា កោះនេះស្ថិតនៅក្រោមការគ្រប់គ្រងត្រួតត្រារបស់ខ្មែរជានិច្ចរៀងដរាបមកជាភស្តុតាងមាន:



-លិខិតលេខ ១១៣៤-DG/DM/X ចុះថ្ងៃទី ២០ កក្កដា ១៩៧២ របស់រដ្ឋមន្ត្រីឧស្សាហកម្មធនធានរ៉ែ និងនេសាទសមុទ្រ ដែលបានផ្តល់ការអនុញ្ញាតឱ្យកាន់កាប់ និងរៀបចំទីនានានៅលើកោះនេះ(ការឈូសឆាយធ្វើកន្លែងមួយសម្រាប់ចុះឡើងឧទ្ធម្ភាចក្រ និងកំពង់ផែមួយ) ដល់ក្រុមហ៊ុនប្រេងឥន្ធនៈ អែលអេរ៉ាប់ របស់បារាំងនៅកម្ពុជា ។ ក្នុងពេលជាមួយគ្នានោះ ក្រុមហ៊ុននេះបានលើក"កំណត់ប្រថពីវិភាគ និងកំណត់ភូមិសាស្ត្រ" ថែមទៀតផង បញ្ជាក់ថា កោះនេះជាកោះរបស់ខ្មែរ មុននឹងចាប់ផ្តើមខួងរកប្រេងរណ្តៅទី១ របស់ខ្លួននៅឆ្នាំ ១៩៧២ ស្ថិតនៅចំងាយប្រមាណ៥០គម ខាងត្បូងកោះនេះ ។

សូមអញ្ជើញមើលរូបថត ដែលបានថតនៅថ្ងៃ ១៩ សីហា ១៩៧២ ក្នុងឱកាសទស្សនិច្ចទីតាំងរបស់ក្រុមហ៊ុន អែលអេរ៉ាប់ នៅកោះពូឡូវៃ នេះ ដោយគណប្រតិភូមួយដឹកនាំដោយលោក ឆាន់ សុខុម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រួមដោយលោក ហេង ឡុង ជានាយកក្រសួងនេះ លោក ស៊ាន ប៉េងសែ នាយកក្រសួងរ៉ែភូគព្ភសាស្ត្រ និងប្រេងឥន្ធនៈនៃក្រសួងនេះដដែល ថតនៅលើកុប៉ាល់របស់កងនាវាចរណ៍ខេមរភូមិន្ទ បើកបរដោយវរនាវីត្រី ។ គណប្រតិភូនេះ ត្រូវបានទទួលដោយលោក ស្វងក្លូត ឡុត ជានាយកក្រុមហ៊ុនប្រចាំប្រទេសកម្ពុជា ។

ត្រូវរំលឹកថា លោក ហ៊ុន សែន ពេលនោះលោកជានាយករដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចុះហត្ថលេខាដោយខុសច្បាប់លើសន្ធិសញ្ញា"ទឹកប្រវត្តិសាស្ត្រជាមួយលោក ង្វៀង កូថាច់ រដ្ឋមន្ត្រីយួន ដែលក្នុងនោះលោក ហ៊ុន សែន ជាលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា បានទទួលស្គាល់ថាកោះត្រល់ និងចង្កោមកោះ ក្រចកសេះ ជាកោះរបស់យួន ឯចំពោះកោះវៃវិញ ថាប្រទេសវៀតណាម ទទួលស្គាល់ថា ជាកោះរបស់ប្រទេសកម្ពុជា ។

ជាថ្មីម្តងទៀត កោះនេះ ពុំដែលជាកម្មសិទ្ធរបស់ប្រទេសវៀតណាមម្តងណានោះឡើយ តែងតែស្ថិតនៅក្រោមការគ្រប់គ្រងត្រួតត្រារបស់ប្រទេសកម្ពុជាជានិច្ចរហូតមក ទោះបីក្នុងសម័យព្រះរាជាណាចក្រកម្ពុជានៃសម្តេច នរោត្តម សីហនុ ក៏ដូចជានៅក្នុងរបបសាធារណរដ្ឋខ្មែររបស់លោកឧត្តមសេនីយ៍ លន់នល់ ដូចនោះដែរ (សូមមើលសេចក្តីចម្លងលិខិតមួយរបស់ក្រសួងឧស្សាហកម្មទៅក្រុមហ៊ុនបារាំង អែល ដែលមានខាងលើនេះស្រាប់) ។

តាមពិត យួនបានចូលមកកាន់កាប់ដោយខុសច្បាប់ និងមួយរយៈពេលខ្លីលើកោះនេះ គឺពីថ្ងៃទី ១០ ខែ មិថុនា ១៩៧៥ ដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំដដែលប៉ុណ្ណោះ កាលក្នុងសម័យរបបខ្មែរក្រហម ប៉ុលពត ។

**តទៅលេខក្រោយ**

---

តមកពីទំព័រទី ១១

## ថ្វាយព្រះពរដល់សម្តេចឪ សម្តេចតា...

**ប្រេត ឌី :** ហ្នឹងហើយខ្ញុំនៅតែបន្តទទួលស្គាល់ថា ទោះជាមាន ព្រឹត្តិការណ៍នយោបាយដ៏កំសត់ នឹងយ៉ាប់យ៉ឺននៅក្នុងអតីតកាលក៏ដោយ សម័យសង្គមរាស្ត្រនិយម ក្រោមរជ្ជកាលនរោត្តម សីហនុ ជាទូទៅខ្ញុំបញ្ជាក់ថា"ជាទូទៅ"ជាសម័យសន្តិភាព សម័យរីករាយ នឹងជាសម័យនៃអនុស្សាវរីយ៍ដ៏ទន់ភ្លន់សម្រាប់គ្នាយើងជាច្រើន។

ដោយសារព្រះអង្គ ប្រទេសកម្ពុជាមុនឆ្នាំ ១៩៧០ ច្បាស់ជាមានសន្តិភាពជាងចំរើនជាងដែលយុវជនជំនាន់យើង ជាពិសេសអ្នកចេញពីគ្រួសារក្រីក្រគ្មានយសស័ក្តអាចរៀនសូត្រយ៉ាងសុខ នឹងសេរីខ្ញុំមិនឃើញថា ដើមឈើមួយអាចលាក់ព្រៃបានទាំងមូលទេ។

**សង្ខារ អ៊ុប :** អនុស្សាវរីយ៍ដ៏ផ្អែមល្ហែមនៃសន្តិភាពនឹងការសប្បាយរីករាយ! ខ្ញុំគ្មានអ្វីនឹងអត្ថាធិប្បាយទេ។

**ផ្កា ហៃមវឿន :** ខ្ញុំយល់ស្របតាមប្រេត ឌីពីអនុស្សាវរីយ៍ផ្អែមល្ហែមនៃសន្តិភាពនឹងរីករាយចំនួន១៦ឆ្នាំ(១៩៥៤-១៩៧០)ក្នុងរជ្ជកាលស្តេចឪ គឺជា១៦ឆ្នាំដែលខ្ញុំសន្មត់ថា ជាសម័យដ៏ប្រសើរបំផុតសម្រាប់ជីវិតខ្ញុំ-ក៏ប៉ុន្តែនរណាក៏ដឹងថា បន្ទាប់ពី១៨ឆ្នាំមិនា ឆ្នាំ១៩៧០ ប្រទេសយើងធ្លាក់ទៅក្នុងព្រឹត្តិការណ៍ខ្មៅខ្មាំដោយសារការស្អប់ខ្ពើមយ៉ាងឃោរឃៅ នឹងភាពល្ងីងជ្ងចត់យ៉ាងជ្រាលជ្រៅរបស់ស្តេចឪ ចំពោះ លន់ នល់ ដែលមិនឈប់ឈរនឹងវាយបណ្តេញយៀកកុងចេញពីទឹក ដី។

តាមយោបល់ខ្ញុំ ទោះជាសុគតទៅហើយក្តី សីហនុ មិនអាចគេចផុតពីការទទួលខុសត្រូវចំពោះការសម្លាប់ជនជាតិខ្លួនឯងអស់បីលាននាក់នៅពេលដែលប៉ុលពតត្រួតត្រា ដែលជាមេដឹកនាំចលនារំដោះខ្មែរក្រហមនោះទេ គេបានចារក្នុងប្រវត្តិសាស្ត្រខ្មែររួចហើយ ៕

តមកពីទំព័រទី ៣

## សូមលោកអ្នកចេញទៅបោះឆ្នោត...

សម្ងាត់។

នៅថ្ងៃដដែលនោះលោកអ្នកនឹងត្រូវបោះឆ្នោតឱ្យមន្ត្រីក្នុងក្រុងរបស់ខ្លួនដែលចប់អាណត្តិសន្លឹកឆ្នោតនោះនឹងបញ្ចប់អាណត្តិ ហើយរើសអ្នកថ្មីដែលគ្រាន់បើមកជំនួស ឬក៏បោះឆ្នោតបន្តឱ្យមន្ត្រីដដែលនៅធ្វើការតទៅទៀត បំរើក្រុងរបស់ខ្លួន ។ ឃើញទេ ថាតើការបោះឆ្នោតរបស់លោកអ្នកមានសារៈសំខាន់ប៉ុណ្ណា? សម្រាប់បេក្ខជននឹងចងភ្ជាប់អនាគតនៃគ្រួសារលោកអ្នក?

នៅ២សប្តាហ៍មុនថ្ងៃបោះឆ្នោត ស.រ.អា ក្រុមអ្នកឯកទេសខាងទស្សទាយ តាមការស្រាវជ្រាវបានឱ្យតម្លៃខុសៗគ្នា ដូចជាពីសកលវិទ្យាល័យកូឡូរ៉ាដូ បានវាយតម្លៃថា មីត រ៉មនី និងឈ្នះឆ្នោតដោយបានឆ្នោតតំណាង៣២០(Electoral Votes) នឹង បារ៉ាក់ អូបាម៉ា បានតែ២១៨។ ក៏ ប៉ុន្តែការទស្សទាយមួយទៀត ការវិភាគផ្សេងគ្នាបានឱ្យបារ៉ាក អូបាម៉ា ឈ្នះដោយបានឆ្នោតតំណាង ២៥៧ ទល់នឹង មីត រ៉មនី តែ១៩១ សម្លេង ។ ហើយសម្លេងទាំងសង្ខាងនៅតែរំកិលឡើងចុះ រៀងរាល់ថ្ងៃរហូតដល់ថ្ងៃបោះឆ្នោត ។ រីឯការស្ទង់មតិជុំវិញ ស.រ.អា មួយទៀតបានឱ្យតម្លៃថា អូបាម៉ា ទទួលការគាំ៤៦ភាគរយច្រើនជាង រ៉មនី ដែលទទួលបានតែ៤៥ភាគរយតែប៉ុណ្ណោះ។

**ការសង្កេតខ្មែរថ្មស :** នៅពេលដែលសម្លេងគាំទ្រនៅប្រកិតគ្នាតែ១ភាគរយតែប៉ុណ្ណោះនោះ សម្លេងឆ្នោតជាពលរដ្ឋអាមេរិកាំងភាគតិច រឹតតែមានតម្លៃខ្ពស់ ពីព្រោះថា បើអ្នកទាំងនោះសម្រុកបោះឆ្នោតឱ្យនរណាម្នាក់នោះ អ្នកនោះនឹងឈ្នះជាមិនខាន។ ដូច្នេះ ជាការប្រសើរណាស់ដែលសហគមន៍ខ្មែរ ត្រូវពិគ្រោះគ្នា ហើយមូលមតិគ្នាប្រកាសគាំទ្របេក្ខជនណាម្នាក់ ដែលយកចិត្តទុកដាក់សហគមន៍ខ្លួន ។ សមាគមខ្មែរនៃតំបន់នីមួយៗ ប្រាកដជាមានឯករាជ្យភាពនឹងអព្យាក្រឹត្យភាពគ្រប់គ្រាន់ សំរាប់ជាអ្នកដឹកនាំពិគ្រោះយោបល់ដ៏ត្រឹមត្រូវ ជាជំនួយដល់សហគមន៍ខ្មែរបាន៕

តមកពីទំព័រទី ១៧

## ទស្សនៈមតិជុំវិញការសោយទិវង្គត...

ឱ្យជួយបង្អាត់ហ្វឹកហ្វឺនក្រុមខ្មែរយៀកមិញ និងជួយចូលរួមវាយប្រយុទ្ធផ្ដួលរំលំជនក្បត់ជាតិ លន់ នល់ សិរីមតៈ ឱ្យបានជោគជ័យនៅក្នុងពេលឆាប់ៗខាងមុខ។

៣-ព្រះអង្គត្រូវតែរំលាយអំណាចរាជានិយមចោលហើយនៅពេលណាព្រះអង្គបានទទួលជ័យជំនះ នៅក្នុងពេលតស៊ូផ្ដួលរំលំបន លន់ នល់ សិរីមតៈ ក្បត់ជាតិឆ្កែបំរើចក្រពត្រអាមេរិកាំងនេះជាស្ថាពរហើយនោះ។

ដោយសារតែការប្ដេជ្ញាយ៉ាងហ្មឹងហ្មត់ដាច់ខាតនេះហើយ ទើបកងទ័ពខ្មែរយៀកមិញ ត្រូវតែបង្កើតឡើងទៅចូលរួមដៃ ជាមួយកងទ័ពព្រៃយួនយៀកកុង ជាច្រើនម៉ឺននាក់ បានបើកការប្រយុទ្ធវាយសំរុកយ៉ាងខ្លាំងក្លាបំផុត ដើម្បីកាន់កាប់ត្រួតត្រាបណ្ដាខេត្តទាំងអស់ ស្ថិតនៅខាងកើតទន្លេមេគង្គ តាមបណ្ដោយព្រំដែន ចាប់តាំងពីខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង តាកែវ កំពត ត្រូវបានធ្លាក់ទៅក្នុងកណ្ដាប់ដៃកងទ័ពព្រៃយួនយៀកកុងទាំងស្រុងនៅដើមឆ្នាំ១៩៧០ នោះទៅ។

ការប្រយុទ្ធសម្លាប់គ្នា ស៊ីសាច់ហុតឈាមរហូតមកដល់ថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ទើបកងទ័ពព្រៃខ្មែរក្រហមយៀកមិញ រួមកម្លាំងគ្នាជាមួយកងទ័ពព្រៃយួនយៀកកុង ដោយមានជួយយ៉ាងខ្លាំងក្លាពីកងទ័ពចិនកុម្មុយនីស្ត កងទ័ពកូរ៉េកុម្មុយនីស្ត បានវាយលុកផ្ដាច់ព្រ័ទ្ធ ចូលកាន់កាប់ក្រុងភ្នំពេញ និងប្រទេសខ្មែរទាំងមូល ក្រោមចុងការណុងជាស្ថាពរនោះទៅ។

ចាប់តាំងពីថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥នោះ ហើយដែលនរោត្តមសីហនុ អតីតព្រះប្រមុខរដ្ឋ ត្រូវបានកងទ័ពខ្មែរក្រហមយៀកមិញ លើកតាំងឱ្យបន្តព្រះតំណែងជាព្រះប្រមុខរដ្ឋ នៃសាធារដ្ឋកម្ពុជា ប្រជាធិបតេយ្យដែលមានវីរៈជនសំខាន់ៗដូចជា ខៀវសំផន ប៉ុលពត អៀងសារី នួនជា ជាដើម បានរៀបចំជារដ្ឋាភិបាលក្រោមការត្រួតត្រាពីកងទ័ពព្រៃយួនយៀកកុង ពីរដ្ឋាភិបាលចិនប្រជាមានិត និងពីរដ្ឋាភិបាលកូរ៉េប្រជាធិបតេយ្យ មានន័យថា ជារដ្ឋាភិបាលរណបពេញទីរបស់ចិនយួន និងកូរ៉េកុម្មុយនីស្តទាំងស្រុង។





នៅក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ ដែលក្រុមខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យត្រួតត្រានេះ ជីវិតជនជាតិខ្មែរជាពិសេសបណ្ដាបញ្ញាវ័ន្តសំខាន់ៗមានចំណេះវិជ្ជា និងបណ្ដាសក្ដិខ្ពង់ខ្ពស់ច្រើនណាស់ត្រូវបានសម្លាប់ចោលយ៉ាងរង្គាលអស់ប្រមាណជិត៤លាននាក់ ដែលបានសម្លាប់តាំងពីឆ្នាំ១៩៧០មកនោះ។

នៅក្នុងព្រឹត្តិការណ៍ដ៏មហាសោកនាដកម្មមហារងទុក្ខវេទនាខ្លោចផ្សា មហាព្រាត់ប្រាស់នៃក្រុមគ្រួសារជាតិខ្មែរ ដែលស្ថិតនៅក្រោមអំណាច ព្រះប្រមុខរដ្ឋសីហនុ ព្រះអង្គមានកំហុសឬទេ នៅក្នុងព្រឹត្តិការណ៍ដ៏មហាសោកនាដកម្មរបស់បណ្ដាប្រជាពលរដ្ឋខ្មែរទាំងអស់នោះ?

នៅក្នុងចំណោមបណ្ដាប្រជាពលរដ្ឋខ្មែរ សព្វថ្ងៃដែលបានរស់នៅក្នុង និងក្រៅប្រទេសរូបខ្ញុំជឿជាក់ថា នឹងត្រូវតែមានបែបទស្សនៈ មតិយល់ឃើញ២យ៉ាងផ្ទុយដាច់ស្រឡះពីគ្នា ជាពិតប្រាកដណាស់គឺ :

ទស្សនៈមតិយល់ឃើញទី១ថា ព្រះអតីតមហាក្សត្រព្រះបាទសម្ដេចនរោត្តមសីហនុ គឺពិតជាព្រះបរមបវរព្រះមហាក្សត្រខ្មែរ ១ព្រះអង្គមានព្រះបញ្ញាណមហាគតិបណ្ឌិតអស្ចារ្យខ្លាំងណាស់ ព្រះអង្គតែងតែមានព្រះរាជហឫទ័យប្រកបដោយព្រះឧត្តមគតិ សតិស្មារតី មនសិការស្នេហាប្រទេស និងប្រជាជាតិខ្មែរពិតប្រាកដណាស់ ដែលបណ្ដាប្រជាពលរដ្ឋខ្មែរទាំងអស់បាន ទុកព្រះអង្គជាសម្ដេចឪ សម្ដេចតា សម្ដេចតាទួត សម្ដេចតាលួតថែមទៀតផង។

ហើយជាពិសេសអ្នកដែលគោរពស្រឡាញ់ដោយស្មោះត្រង់ជាងគេបំផុត គឺជានាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវជាព្រះរាជបុត្រធម៌របស់ព្រះអង្គ ដែលបានប្រទានបរមងារដល់នាយករដ្ឋមន្ត្រីខ្មែរថា សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន រហូតមកថ្ងៃនេះ៕


# ក្រុមហ៊ុនធានារ៉ាប់រងដែលបាន បំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com



# East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្នងច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

# សុខភាពល្អប្រសើរក្នុងដៃលោកអ្នក

បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រពុកខ្លាំង -មានស្ករច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្តិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។ ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។




លោក វិចិត្រ ភូស៊ីវ៉ុខ ៦២ឆ្នាំ មុនប្រើ "អេមស្តា" គាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាធើរី"-ឈឺសន្លាក់ ដៃជើង ឈឺក្រពះ...។ល។

**បន្ទាប់ពីបានប្រើ "អេមស្តា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្តើរបាន-បីខែក្រោយទៀតសរសៃឈាម២ពែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពហ្វឹងធំល្អឡើងវិញ ។

**ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ**
-ហ្វីឡាខាងត្បូង ២១៥ ២៣៧ ៥៧០៥ សាមន់ថា
-ហ្វីឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ វ៉ើរ



# Accepting New Clients

សូមស្វាគមន៍ដល់ភ្ញៀវគ្រប់ប្រភេទ

Immigration • Divore • Auto Crash

អន្តោប្រវេសន៍ គ្រោះថ្នាក់រថយន្ត លែងលះប្តីប្រពន្ធ

**Law Office of Thomas Stylianos Jr. • 287 Appleton St. Lowell MA 01852**

ការិយាល័យ មេធាវី ថូម៉ាស ស្តាលីយ៉ាណូស

Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា, ឬ ថំ

**978-459-5000 or 800-308-3766**

Only Licensed in Massachusets


## តមកពីទំព័រទី ១៧ ការយាងចូលទីវង្គត...(Cambodia Daily)

ដង្ហែព្រះសពនៅមុខទ្វារព្រះបរមរាជវាំង ។

នៅខណៈពេលព្រះបរមសពនៃព្រះមហាវីរក្សត្របានចូលមកដល់ក្នុងបរិវេណព្រះបរមរាជវាំងអំពូលភ្លើងពណ៌លឿង ដែលដាក់នៅតាមកំពែងព្រះបរមរាជវាំងត្រូវបានបើកបំភ្លឺឡើង។ បន្ទាប់ និងធ្វើពិធីបូជា លើវាលព្រះមេរុខាងមុខសារមន្ទីរជាតិ ។

ដោយជូតទឹកភ្នែកចេញពីថ្ពាល់អ្នកស្រី ភឿន វណ្ណ អាយុ៤០ឆ្នាំអញ្ជើញមកពីខេត្តកណ្តាល បានរំលឹកអំពីការដឹកនាំរបស់ព្រះមហាវីរក្សត្រនរោត្តម



ប្រជាពលរដ្ឋយ៉ាងពពាក់ពពូននៅមុខទ្វារព្រះបរមរាជវាំងបានចាប់ផ្តើមបំបែកគ្នា និងដើរទៅកាន់កន្លែងដាក់ព្រះឆាយាលក្ខណ៍របស់ព្រះមហាវីរក្សត្រតាំងនៅមុខព្រះបរមរាជវាំង ។

ព្រះបរមសពរបស់សម្តេចឪ និងត្រូវតម្កល់ទុកយ៉ាងហោចណាស់រយៈពេល៣ខែ ហើយ សីហនុ ។ អ្នកស្រីបន្តថា "ឥឡូវនេះព្រះអង្គបានយាងចូលទីវង្គតហើយ ខ្ញុំមិនមានអារម្មណ៍ឬទំនុកចិត្តចង់ទៅបោះឆ្នោតទេ" ។ អំឡុងពេលក្រោមរបស់ព្រះអង្គខ្ញុំមិនធ្លាប់ពិបាកអ្វីចឹងទេ ។ យើងរស់នៅយ៉ាងសប្បាយ ។ អ្វីៗថោកជាងនេះឆ្ងាយណាស់ ៕


# ANGKOR AUTO SERVICE,INC.

ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



BODY WORKS

Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្ហួរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.



4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425





# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe´s Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# KhmerPost USA

Printing The Cambodian World News

## Print Edition now available on the web at:

## www.khmerpost.us

## Impact of the KhmerPost USA




The KhmerPost USA is the only Cambodian newspaper has the highest circulation and is most read in the Cambodian communities in the East Coast of United States. The newspaper prints between 24 to 32 pages an issue. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement.

Found in 2007 by a respectable Cambodian Journalist, Roger Samkhon Pin, who is the former President of Cambodian Journalist Association of Cambodia, the former Director of Radio Free Asia, Cambodian Services in Washington D.C, and the former owner and broadcaster of Cambodian-American news through five Radio Stations around the U.S. He is very well respected as an independent journalist around the country and the world by the Cambodian people. Consequently, the KhmerPost USA newspaper was quickly spread readerships upon its inception in Philadelphia, Pennsylvania in 2007 and we built a branch to serve the New England States in summer 2010.

- **Publication Frequency:** 24 times a year. Prints on every other Friday
- **Circulations**: 20,000 copies per month for FREE.
- **Distributions:** nearly 300 locations in Philadelphia, New Jersey, Rhode Island, and Massachusetts.
- **Readership:** 50,000+ and is growing to Connecticut in summer 2012.
- **Publication Stock**: #35, Binding: Tabloid, Printing Process: Web press

### 2012 Publication Schedules

| | | | |
|---|---|---|---|
| May 4th, 2012 | May 25th, 2012 | September 7th, 2012 | September 21st, 2012 |
| June 8th, 2012 | June 22nd, 2012 | October 5th, 2012 | October 19th, 2012 |
| July 6th, 2012 | July 20th, 2012 | November 9th, 2012 | November 23rd, 2012 |
| August 3rd, 2012 | August 24th, 2012 | December 7th, 2012 | December 21st, 2012 |

**Deadline: the advertising artwork deadline is three days prior to the publication date.**
**Cancellations:** Cancellation for space reservations are not accepted after closing dates. All Cancellation must be made in writing by five days before publication date.

**Advertising Department**
**KhmerPost USA, LLC**
Headquarter. 438 Lindley Avenue. Philadelphia, PA 19120
MA Branch. 217 Appleton St. Lowell, MA 01852
Direct: 267-253-3947 Phone/Fax: 215-722-2226
Email: KhmerPostUSA@gmail.com
Website: www.khmerpost.us

# សមាគមខ្មែរនៅ"កូណេទីកិត"ប្រារព្ធខួប៣០ឆ្នាំ


លោកស្រី ធានវី គុជ


លោក សេងលី គង់ ពិធីករ

**ខ្មែរផុស ស.រ.អា**

**កូណេទីកិត :** ខ្មែរនិងអាមេរិកាំងប្រមាណ ៣០០នាក់បានចូលរួមយ៉ាងអធិកអធម ដើម្បីរំលឹកខួបទី៣០នៃ"សមាគមគាំទ្រសុខភាពខ្មែរ" (Khmer Health Advocate) កាលពីរាត្រីថ្ងៃទី៧ខែឧសភា ឆ្នាំ២០១២ទៅដោយមានក្រុមតន្ត្រីសម័យដ៏ល្បីឈ្មោះបីក្រុមចូលរួមកំដរផង គឺទី១ ក្រុមតន្ត្រី ហេឡូ មកពីតំបន់រដ្ឋធានីវ៉ាស៊ិនតោន ដែលបានផ្តើមសកម្មភាពសិល្បរបស់ខ្លួនតាំងតែពីនៅជំរុំខាវអ៊ីដង ហើយបន្តបំពេអារម្មណ៍សមាគមខ្មែរអាមេរិករហូតដល់ថ្ងៃនេះយ៉ាងល្បីល្បាញ ទី២ក្រុមតន្ត្រីគ្រួសារអ្នកស្នេហាតន្ត្រីមកពីញូវយ៉ក ដែលក្នុងនោះមានឪពុកជាអ្នកកាន់ពីយ៉ាណូ ម្តាយជាអ្នកចំរៀង និងកូនស្រីអ្នកវាយស្គរយ៉ាងចំណាប់ តាំងពីអាយុ៩ឆ្នាំឥឡូវអាយុ១៩ឆ្នាំហើយ ក្រុមទី៣គឺក្រុមតន្ត្រី"មនុស្សដូចខ្ញុំ"(the Like me´s) ដែលរួមប្រជុំដោយអ្នកភ្លេងយុវនារី៤នាក់ហើយ ក៏ជាអ្នកចំរៀងផងដែរ គឺក្រុមយុវនារីតន្ត្រីករខ្មែរអាមេរិកាំង តាំងពីដំបូងបង្អស់ដែលមានអាជីពជាសិល្បករ ហើយមានកុងត្រាដើម្បីសម្តែងប្រចាំឆ្នាំនៅកម្ពុជាទៀតផង ។ ទាំងអ្នកភ្លេងទាំងភ្ញៀវអ្នកឡើងរាំ ទាំងអ្នកបរិភោគ បានបង្ហាញនូវអនុស្សាវរីយ៍ នៃវប្បធម៌ខ្មែរកំពង់បន្តដំណើរទៅស.រ.អា យ៉ាងពេញទំហឹងដោយអារម្មណ៍រីករាយ ឥតឧបមា ពេលខ្លះទៀតក៏បញ្ចេញនូវរបាំចំរុះវប្បធម៌ ប្រកបដោយមោទនភាពខ្លាំងក្លាណាស់ដែរ ដែលទាំងនោះបង្ហាញនូវសញ្ញានៃជោគជ័យក្នុងសមាគមខ្មែរនៃជនជាតិភាគតិចនៅឯបរទេស យ៉ាងគួរឱ្យចាប់អារម្មណ៍ផងដែរ ។




the Like me´s

ថ្វីត្បិតតែក្នុងសញ្ញានៃជោគជ័យរបស់សមាគមក៏ដោយ លោកស្រីនាយកប្រតិបត្តិ ធានវី គុជ និយាយថា"នៅមានការងារបំរើសុខភាពផ្លូវចិត្តសហគមន៍យ៉ាងមមាញឹកនៅឡើយ" លោកស្រីបានរំលឹកយ៉ាងនេះថា"កាលពីជាង៣០ឆ្នាំមុនយើងបាននាំគ្នាចេញពីព្រៃដើរចូលជំរុំភៀសខ្លួននៅថៃ...យើងបានស្រេកឃ្លាន យើងរងរបួសអស់ពេលដ៏យូរតែគ្មាននរណាបានជឿថា មានរឿងយ៉ាងនេះ អាចកើតឡើងក្នុងអំឡុងបីឆ្នាំ៨ខែ ២០ថ្ងៃ នោះទេ ក៏ប៉ុន្តែវាក៏ប្រវត្តិនេះ ស្ថិតនៅជាបបេះដូងយើងម្នាក់ៗនៃក្តីសង្ឃឹមដែរ" ។

ជាសហស្ថាបនិកសមាគមជាមួយជាមួយលោកស្រីMary Scully នឹងវេជ្ជបណ្ឌិតចិត្តសាស្ត្រ រីករើតមីល័រ(Richard Millor) លោកស្រី ធានវី គុជ

**តទៅទំព័រទី ១៨**

បានចូលរួមបំរើសហគមន៍ខ្មែរ តាំងពីឆ្នាំ១៩៨២ ដើម្បីណែនាំ នឹងជួយព្យា **តទៅទំព័រទី ១៨**




